ក្រសួងអប់រំ យុវជន និង កីឡា

# ១៤ សមាហរណកម្មសហគមន៍

# បញ្ឈប់ពលកម្មកុមារ

## ការពារសិទ្ធិកុមារតាមរយៈការអប់រំ_សិល្បៈ និងប្រព័ន្ធផ្សព្វផ្សាយ

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

អង្គការពលកម្មអន្តរជាតិ

២០០៧

## វត្ថុបំណង ៖



បង្កើនការចាប់អារម្មណ៍ និងការចូលរួមក្នុងគំរោងពលកម្មកុមារពីសហគមន៍ខាងក្រៅ ។

## លទ្ធផលរំពឹងទុក ៖



បង្កើនការយល់ដឹងអំពីពលកម្មកុមារនៅក្នុងសហគមន៍ធំ ។ រិះរកវិធីឱ្យមានការចូលរួមពីក្រុមផ្សេងៗដូចជាបន្តការធ្វើអោយមានការយកចិត្តទុកដាក់ និងមានចំណាប់អារម្មណ៍លើគំរោងនេះនិងលើបញ្ហាពលកម្មកុមារ ។ ពង្រឹងតួនាទីរបស់យុវជនឱ្យទៅជាភ្នាក់ងារនៃការប្រមូលកម្លាំង និងការផ្លាស់ប្តូរសង្គម ។

## ការកំណត់ពេលវេលា

បង្រៀន ២ ទៅ ៣ ដង ។ ការកំណត់រយៈពេលអោយបានច្បាស់សំរាប់ធ្វើលំហាត់នេះ គឺជាការលំបាកមួយ ព្រោះវាអាស្រ័យលើកាលៈទេសៈរៀងៗខ្លួនរបស់បុគ្គលនីមួយៗ និងសកម្មភាពដែលយើងសម្រេចនិងធ្វើដើម្បីបង្កើនការយល់ដឹងអំពីវា ។ អ្នកអាចបង្កើតអោយមានឡើងនូវ "ថ្ងៃពលកម្មកុមារ" ពិសេសមួយ ឬក៏ធ្វើសកម្មភាព បង្កើនការយល់ដឹងជាបន្តបន្ទាប់ក្នុងរយៈពេល ១ សប្តាហ៍ ។ យ៉ាងណាមិញ គួរកត់សំគាល់ថាភាគច្រើននៃសកម្មភាពទាំងអស់នេះ ទាមទារអោយមានគំរោងនិងការរៀបចំជាមុនអោយបានល្អ និងគួរទុកពេលវេលាអោយបានសមរម្យ សំរាប់ការងារខាងលើនេះក៏ដូចជាសំរាប់ព្រឹត្តិការណ៍នានាផងដែរ ។



## កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

យើងសូមណែនាំថា ម៉ូឌុលនេះគឺជាម៉ូឌុលចុងក្រោយដែលអ្នកនឹងយកទៅអនុវត្តដោយសារតែវាប្រមូលផ្តុំគ្រប់សកម្មភាពដែលអ្នក និងក្រុមរបស់អ្នកបានធ្វើនៅក្នុងម៉ូឌុលមុនៗ ។ មូលដ្ឋាននៃកម្មវិធី SCREAM គឺជាការអភិវឌ្ឍន៍ និងការបង្កើនការយល់ដឹងអោយបានខ្ពស់អំពីសហគមន៍ ។ ម៉ូឌុលនេះផ្តល់នូវការគាំទ្រចំពោះអ្នកដែលអាចទទួលយកគំនិតនេះ បានតាមលទ្ធភាពរបស់គេ និងផ្តល់ឱកាសដល់យុវជន អោយទទួលយកតួនាទីជាភ្នាក់ងារអនុវត្តដោយប្រើកំលាំងសរុបសង្គម និងធ្វើអោយមានការប្រែប្រួលក្នុងសង្គម ។ ម៉ូឌុលនេះអាចផ្តល់បទពិសោធន៍ដ៏ធំធេង និងដ៏រំភើបមួយសំរាប់ពួកគេ ។ នេះជាឱកាសមួយដ៏ថ្លៃថ្លាសំរាប់ អោយពួកគេទទួលយក ។

# ហេតុផល



ម៉ូឌុលទាំងឡាយនៃកម្មវិធី SCREAM ត្រូវបានរៀបរៀងឡើងដើម្បីឱ្យក្រុមយុវជនចូលរួមយ៉ាងសកម្មក្នុងយុទ្ធនាការជាសាកលមួយ ដើម្បីលុបបំបាត់ពលកម្មកុមារ ។ តាមរយៈការយល់ដឹងដែលទទួលបាន ក្រុមយុវជនទាំងនោះនឹងត្រូវបានផ្តល់អំណាច ដើម្បីបញ្ជូលសារនេះបន្ត១គ្នាដល់ ក្រុមដែលមានអាយុស្របាល១នឹងគ្នា គ្រួសារ និងសហគមន៍របស់ពួកគេ ។ តាមរយៈនៃការអនុវត្តតាមម៉ូឌុលទាំងនេះ យើងចង់អោយយុវជនទាំងនោះដឹងថា ពួកគេមានតួនាទីយ៉ាងសំខាន់ក្នុងការលុបបំបាត់ពលកម្មកុមារ ហើយផ្នែកមួយនៃតួនាទីនេះគឺជាសមត្ថភាពដែលអាចអោយពួកគេយល់អំពីទឹកចិត្ត និងការរស់នៅរបស់សមាជិកដទៃទៀតនៅក្នុងសហគមន៍ជុំវិញពួកគេ និងជួយក្មេង១ អោយរួចផុតពីការកេងប្រវ័ញ្ចនៅលើពិភពលោក ។

យើងមានវិធីថ្មី១ប្រកបដោយការច្នៃប្រឌិតជាច្រើន ដើម្បីបញ្ជូលសមាជិកដទៃទៀតនៃសហគមន៍ទៅក្នុងកម្មវិធី SCREAM ។ អ្នកប្រហែលជាបានយល់ពីវិធីទាំងនេះ ហើយនៅពេលដែលអ្នកបានអនុវត្តមេរៀននានានោះ ។ ជាឧទាហរណ៍ យើងតែងតែពិភាក្សារកការគាំទ្រពីអ្នកខាងក្រៅ ដូចជាការគាំទ្រពីឪពុកម្តាយ លោកគ្រូអ្នកគ្រូ ឬពីអ្នកជំនាញការនានា ។ យើងក៏ទទូចសុំអញ្ជើញអ្នកនយោបាយមានប្រជាប្រិយភាពនានាក្នុងតំបន់ សហជីពពាណិជ្ជករ ពាណិជ្ជករនាំមុខគេ សមាជិកអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលនានាផ្សេងទៀតឱ្យមកណែនាំក្រុមរបស់យើងអំពីប្រធានបទណាមួយ ឬត្រួតពិនិត្យ និងចូលរួមក្នុងសកម្មភាពផ្សេង១ ។ យើងពិភាក្សារិះរកការទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយនានា និងរៀបចំយុទ្ធនាការផ្សព្វផ្សាយមួយ ។ សូម្បីតែម៉ូឌុលអំពីការសំដែងអាចប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពក្នុងការធ្វើអោយមានការចូលរួមពីសហគមន៍ ។ ក្រុមយុវជននឹងត្រូវបានលើកទឹកចិត្តអោយសំដែងជាតួអង្គជំនួសអ្នកដទៃនៅក្នុងសហគមន៍ ហើយពេលនោះពួកគេនឹងអាចពាំនាំនូវសារនេះទៅកាន់ទស្សនិកជនផ្សេង១ទៀតផងដែរ ។ សំណូមពរដទៃទៀតដើម្បីសកម្មភាពអភិវឌ្ឍន៍សហគមន៍ដែលកំពុងដំណើរការមានពន្យល់លំអិតនៅក្នុងម៉ូឌុលសំរាប់អ្នកប្រើប្រាស់ ។

ម៉ូឌុលនេះមានគោលបំណងជួយអ្នក និងក្រុមរបស់អ្នកអោយបង្កើតសកម្មភាពលើកកំពស់ការយល់ដឹងមួយ ជាពិសេសឬជាបន្ទបន្ទាប់ ។ នៅក្នុងឧបសម្ព័ន្ធ ១ អ្នកនឹងបានអានករណីសិក្សាមួយអំពីសប្តាហ៍នៃការយល់ដឹងពីសហគមន៍ ដែលបានប្រព្រឹត្ត

ឡើងនៅក្នុងរយៈពេលកំពុងអនុវត្តគំរោងសាកល្បងនៃម៉ូឌុលនានា នៅសាធារណរដ្ឋអៀរឡង់ ។

## ការរៀបចំ



ជំនួយពីខាងក្រៅ

យើងមានវិធីច្រើនយ៉ាងផ្សេងៗគ្នា ដើម្បីលើកកំពស់ការយល់ដឹងអំពីសហគមន៍មួយ ។ វិធីមួយចំនួនត្រូវបានពណ៌នានៅក្នុងករណីសិក្សាលំអិតនៃឧបសម្ព័ន្ធ ១ ។ សកម្មភាពទាំងឡាយពឹងផ្អែកទៅលើបរិបទ និងបរិស្ថានរៀងៗខ្លួន ។ កត្តាផ្សេងៗ ដូចជាប្រពៃណី វប្បធម៌ ធនធាន កាតព្វកិច្ច បុព្វហេតុនឹងដើរតួយ៉ាងសំខាន់នៅក្នុងសកម្មភាពដែលអ្នកត្រូវធ្វើ ។ ទោះជាយ៉ាងណាក៏ដោយបញ្ហាគន្លឹះគឺថាយុវជននៅក្នុងក្រុមត្រូវតែបានចូលរួមក្នុងការសំរេចចិត្តទាំងអស់នេះ ។

សកម្មភាពខ្លះដែលអ្នក និងក្រុមរបស់អ្នកត្រូវធ្វើអាចនឹងមានប្រសិទ្ធភាពកាន់តែខ្លាំងឡើង បើសិនជាមានការជួយជ្រោមជ្រែងពីសមាជិកនានានៅក្នុងសហគមន៍ ។ ជាឧទាហរណ៍ ប្រសិនបើក្រុមរបស់អ្នកមានបំណងធ្វើសិក្ខាសាលាអំពីសិល្បៈនៅសាលាបឋមសិក្សាណាមួយក្នុងតំបន់ ឬបង្កើតនូវរូបចំលាក់ដ៏ធំមួយ អ្នកប្រហែលជាត្រូវការជំនួយពីសិល្បករក្នុងតំបន់ ឬលោកគ្រូ អ្នកគ្រូសិល្បៈជាពុំខាន ។ ចូរអ្នកលើកស្មារតីក្រុមរបស់អ្នកដើម្បីរៀបចំការចេញទៅទំនាក់ទំនងជាមួយសមាជិកនានាក្នុងសហគមន៍ដែលអាចផ្តល់អ្នកជំនាញ និងជំនួយក្នុងសកម្មភាពបង្កើនការយល់ដឹងនេះ ។ សិល្បករក្នុងតំបន់មួយចំនួនប្រហែលជាបានចូលរួមសកម្មភាពមុនៗរួចហើយ ។ បើដូច្នេះមែន សូមអោយក្រុមរបស់អ្នកទៅទាក់ទងជាមួយគាត់ជាថ្មីម្តងទៀត ដើម្បីអោយដឹងថាតើគាត់អាចជួយបន្តទៀតបានឬទេ ។

ភ្លេង ចំរៀង និងរបាំគឺជាវិធីមានប្រសិទ្ធភាពយ៉ាងខ្លាំងក្នុងការបង្កើនការយល់ដឹងអំពីសហគមន៍នានា ។ ទាំងក្នុងន័យសិល្បៈ និងការអប់រំ ភ្លេងប្រមូលកំលាំង ដែលនាំមនុស្សគ្រប់ក្រុមអាយុ និងគ្រប់សង្គមឱ្យស្ថិតក្នុងបរិស្ថានមួយប្រកបដោយរមណីយភាព ។ ភ្លេង និងចំរៀងធ្លាប់ត្រូវបានគេប្រើប្រាស់នៅក្នុងសកម្មភាព IPEC មួយចំនួន ដូចជាការនិពន្ធឡើងនូវបទ "ចូរដោះលែងកុមារអោយមានសេរី



ភាព” ដោយក្រុមសិស្សសាលា College Gabriel Peri នៃប្រទេសបារាំង និងការប្រគុំតន្ត្រីដោយក្រុមតន្ត្រី ស៊ុយស៊ុយគី (Suzuki) នៅទីក្រុង Turin នៃប្រទេសអ៊ីតាលី ។ តាមវិធីទាំងនេះ យុវជនអាចយល់ពីទឹកចិត្តរបស់អ្នកដែលធ្វើការសំរេចចិត្តនៅគ្រប់កន្លែងទាំងអស់ ។

ក្នុងឧបសម្ព័ន្ធ ១ អ្នកនឹងបានឃើញនូវឧទាហរណ៏មួយអំពីវិធីដែល ប្រវត្តិវិទូ និង បណ្ឌិតសភាបានចូលរួមក្នុងកម្មវិធីបង្កើនការយល់ដឹងរបស់សហគមន៏ ។ បុគ្គលទាំងអស់នេះអាចជួយក្នុងការពិភាក្សាតុមូលទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយ និងការណែនាំសហគមន៏ ។ ជាឧទាហរណ៏ ក្រុមរបស់អ្នកអាចអញ្ជើញបុគ្គលទាំងនោះមកចូលរួមជាអ្នកដាក់ដេញថ្លៃលក់គំនូរដែលគូរដោយក្រុមសិស្សសាលាបឋមសិក្សានៅក្នុងតំបន់នៅក្រោមប្រធានបទពលកម្មកុមារ ។

សហគមន៏ភាគច្រើនជាអ្នកមានជំនាញមានចំណង់ចំណូលចិត្ត និងមានមុខងារច្រើនយ៉ាង ។ ប្រជាជនភាគច្រើននឹងឆ្លើយជាវិជ្ជមាននៅពេលដែលក្រុមយុវជនទាំងនោះទៅសុំជំនួយដើម្បីការងារមនុស្សធម៌ ការងារអភិវឌ្ឍន៏ និងការងារសង្គម ។ ការងារនេះអាចជួយបង្កើនជំនាញរស់នៅក្នុងសង្គម និងជំនាញទំនាក់ទំនងរបស់ពួកគេផងដែរ ។

## យុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយ

ចូរយើងសង្កត់អោយធ្ងន់ទៅលើសារៈសំខាន់នៃទំនាក់ទំនងជាមួយប្រព័ន្ធព័ត៌មានដើម្បីផ្សព្វផ្សាយសកម្មភាពបង្កើនការយល់ដឹងផ្សេងៗ ។ សូមអោយពួកគេពិនិត្យឡើងវិញនូវការងារដែលពួកគេបានធ្វើសំរាប់ម៉ូឌុលផ្សព្វផ្សាយ ពីព្រោះការងារទាំងនោះអាចជួយការខិតខំរបស់ពួកគេ ដើម្បីទំនាក់ទំនងជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយ នៅពេលមានការងារបង្កើនការយល់ដឹងណាមួយនោះ ។



ការជំរុញលើកទឹកចិត្តក្រុមរបស់អ្នកដើម្បីអោយក្លាហានធ្វើទំនាក់ទំនងជាមួយនឹងប្រព័ន្ធឃោសនា ។ ទំនាក់ទំនងនេះអាចនឹងចំណាយថវិកាយ៉ាងច្រើន ដើម្បីអោយការងាររបស់យើងត្រូវបានគេបោះពុម្ពនៅលើទំព័រកាសែតមួយចំនួន ឬក៏ផ្សាយនៅតាមវិទ្យុ ។ ប្រសិនបើក្រុមរបស់គេបាន រៀបចំការងាររបស់គេបានហ្មត់ចត់នោះ ពួកគេនឹងអាចបញ្ចុះបញ្ចូលនិពន្ធនាយកនៃកាសែត អ្នកយកព័ត៌មាន ឬអ្នកផ្សព្វផ្សាយព័ត៌មានអោយគាំទ្រការងារ និងសកម្មភាពរបស់ពួកគេតាមរយៈការផ្តល់នូវពេលវេលាផ្សព្វផ្សាយដោយតំលៃថោកជាងធម្មតា ឬដោយពុំមានបង់ប្រាក់តែម្តង ។ ពួកគេពុំមាន

ខាតបង់អ្វីឡើងដោយគ្រាន់តែសាកសួរនោះ ហើយជូនកាលប្រព័ន្ធផ្សព្វផ្សាយទាំងនោះ អាចនឹងឆ្លើយយល់ព្រមក្នុងន័យជួយលុបបំបាត់ពលកម្មកុមារ ។ លើសពីនេះទៅទៀត ទំនាក់ទំនងនេះ អាចបង្កើតនូវចំណងមិត្តភាពល្អជាមួយប្រព័ន្ធផ្សព្វផ្សាយទាំងនោះ ហើយពួកគេ នឹងទទួលបានឱកាសយ៉ាងសំខាន់ ដើម្បីផ្សព្វផ្សាយសកម្មភាព និងការងាររបស់ក្រុម ។

## សកម្មភាព ១ : ព្រឹត្តិការណ៍នានាដើម្បីបង្កើនការយល់ដឹង

*បង្រៀនមួយពេលទៅពីរពេល ដើម្បីពិចារណារកគំនិតថ្មីៗ និង រៀបចំសកម្មភាពផ្សេងៗដោយរួមនឹងរយៈពេលដែលត្រូវការសំរាប់សកម្មភាពទាំង នេះ ។*

ចូរអ្នកបង្កើតឡើងនូវការពិភាក្សាជាច្រើនជាមួយនឹងក្រុម ។ សុំអោយពួកគេចូលរួមបញ្ចេញយោបល់របស់គេ និងទុកពេលវេលាសំរាប់អោយពួកគេអាចរិះរកនូវគំនិតថ្មីៗបន្ថែមទៀត ។ អ្នកនឹងឃើញថានាដំណាក់កាលនេះ ក្រុមយុវជនទាំងនោះនឹងមាននូវគំនិតថ្មីៗជាសំណូមពរផ្ទាល់ពីពួកគេ ដើម្បីធ្វើសកម្មភាពបង្កើនការយល់ដឹង ហើយពួកគេនឹងមានចំណង់ធំធេង និងមិនរុញរាចំពោះការងារពាក់ព័ន្ធនេះ ។ នៅពេលដែលគំនិតនានាត្រូវបានកត់ត្រារួចហើយចូរអ្នកនាំគ្នាពិភាក្សាអំពីគំនិតទាំងនោះ ដើម្បីអោយដឹងថា គំនិតណាអាចក្លាយជាការពិតបាន គំនិតមួយណាមានសារៈសំខាន់ជាងគេ ហើយអាចអោយក្រុមទទួលបាន ។ ក្រុមរបស់អ្នកត្រូវស្គាល់កាតព្វកិច្ចរៀងៗខ្លួន គឺមិនគ្រាន់តែបញ្ចេញគំនិតប៉ុណ្ណោះទេក៏ប៉ុន្តែត្រូវរៀបចំអនុវត្តគំនិតទៅជាសកម្មភាព ជាក់ស្តែងថែមទៀត ។



ផ្នែកខាងក្រោមនេះ បង្ហាញវិធីមួយចំនួនសំរាប់សកម្មភាពបង្កើនការយល់ដឹងនេះ ។ ខ្លឹមសារក្នុងឧបសម្ព័ន្ធ ១ មានប្រយោជន៍ខ្លាំងក្នុងការជួយបង្កើតនូវគំនិតថ្មីៗ ការគិតគូរអំពីបញ្ហា និងដោះស្រាយបញ្ហា ។ វិធីខាងក្រោមនេះពុំមែនជាបញ្ជីវិធី ដែលត្រូវបានរៀបចំអោយបានដិតដល់នោះទេ ប៉ុន្តែវានឹងអាចជួយដល់ការពិភាក្សា និង បង្កើតនូវគំនិតថ្មីៗទៀតសំរាប់ក្រុមទាំងមូល ។

- ជ្រើសរើសថ្ងៃពិសេសមួយដើម្បីធ្វើសកម្មភាពបង្កើនការយល់ដឹងនេះ ។ ជំរើសដ៏ល្អមួយនេះគឺយកថ្ងៃប្រារព្ធ "ទិវានៃពិភពលោកដើម្បីប្រឆាំងនឹងពលកម្មកុមារ" ( ថ្ងៃ ទី ១២ ខែ មិថុនា) ។ ឬម្យ៉ាងវិញទៀតអ្នកអាចជ្រើសយកថ្ងៃបោះឆ្នោត

សភាជាតិ ឬបោះឆ្នោតក្រុមប្រឹក្សាភិបាលមូលដ្ឋាន យកថ្ងៃពិសេសមួយនៃអង្គការសហប្រជាជាតិ គឺទិវាពលកម្មអន្តរជាតិ (ថ្ងៃទី ១ ឧសភា) យកថ្ងៃសិទ្ធិមនុស្ស ឬក៏ទិវាដឹងគុណមាតា (ទិវានេះប្រហែលជាអាចជួយរំលឹកដល់កុមារមួយចំនួនដែលបាត់បង់ម្តាយ ឬក៏ត្រូវបានពង្រាត់ចេញពីម្តាយ) ។ ការរៀបចំសកម្មភាពទាំងឡាយនៅពេលដែលមានព្រឹត្តការណ៏សាធារណៈសំខាន់ៗបែបនេះ នឹងមានឥទ្ធិពលខ្លាំងចំពោះសហគមន៏ ។



- ធ្វើការទំនាក់ទំនងជាមួយសាលាបឋមសិក្សាដែលនៅក្បែរនោះ ហើយរៀបចំបើកសិក្ខាសាលាផ្សេងៗ ស្តីពីពលកម្មកុមារជាមួយនឹងសិស្សានុសិស្សទាំងអស់ នៃសាលានោះ ។ សិក្ខាសាលានេះអាចត្រូវរៀបចំឡើងដោយក្រុមយុវជននៅក្នុងក្រុមរបស់អ្នកដោយមានការជួយជ្រោមជ្រែងពីអ្នក លោកគ្រូ អ្នកគ្រូ ឪពុកម្តាយពីសមាជិកដទៃទៀតនៅក្នុងសហគមន៏ ។ សិក្ខាសាលានេះអាចផ្តោតការយកចិត្តទុកដាក់ទៅលើការនិពន្ធបទចំរៀង ឬកំណាព្យស្តីអំពីពលកម្មកុមារ ហើយនៅពេលបញ្ចប់ ក្រុមទាំងមូលអាចចេញទៅច្រៀងស្ងូតវានៅការិយាល័យទីស្នាក់ការក្រុមប្រឹក្សាភិបាលមូលដ្ឋាន ឬ កន្លែងសាធារណៈសំខាន់ៗមួយចំនួន ដែលអាចអោយសហគមន៏បានឃើញនិងបានឮ ។ ឬម្យ៉ាងវិញទៀត ក្រុមរបស់អ្នកអាចរៀបចំបង្កើតឡើងនូវសិក្ខាសាលាស្តីពីសិល្បៈរយៈពេលពេញមួយថ្ងៃនៅសាលាបឋមសិក្សានានា ។ រូបគំនូររូបចំលាក់ ឬស្នាដៃសិល្បៈនានាក្រោមប្រធានបទពលកម្មកុមារអាចត្រូវដាក់តាំងអោយមើលនៅក្នុងសហគមន៏ ឬក៏ដាក់លក់នៅក្នុងពិធីដេញថ្លៃមួយ ដើម្បីបង្កើននូវថវិកាសំរាប់គំរោងពលកម្មកុមារនានា ឬអង្គការផ្សេងៗដែលត្រូវបានបង្កើតឡើងដើម្បីលុបបំបាត់ពលកម្មកុមារ និងជួយកុមារដែលត្រូវគេកេងប្រវ័ញ្ច ។
- កសាងរូបគំរូ ឬរូបសំណាកធំមួយនៅតាមកន្លែងសំខាន់ៗរបស់សហគមន៏ ឬនៅតាមសាលារៀន ។ រូបទាំងនោះតំណាងអោយពលកម្មកុមារ ។ រូបសំណាកនេះ (ដែលអាចជាបង្គោលខ្ពស់មួយ) គួរតែជានិមិត្តរូបនៃអ្វីៗទាំងអស់ដែលអាក្រក់ និងមានគ្រោះថ្នាក់ដល់កុមារ ។ សកម្មភាពចុងបញ្ចប់គួរតែអោយក្រុមយុវជនបំផ្លាញរូបសំណាកនោះ ។ ការបំផ្លាញបែបនេះបង្ហាញនូវកំហឹងរបស់ក្រុមយុវជនទៅលើពលកម្មកុមារ និងទៅលើក្រុមជនដែលនៅតែបន្ត ឬធ្វើព្រងើយកន្តើយនឹងការជិះជាន់នេះ។ រូបសំណាកនោះគួរតែត្រូវបានធ្វើឡើងដោយធាតុដែលបង្កភាពងាយស្រួលក្នុង

ការបំផ្លាញ ឧទាហរណ៍ ធ្វើអំពីក្រដាស់ និងបិទដោយការស្អិតជាដើម ។ ក្រុមអ្នកអាចរៀបចំឡើងនូវពិធីមួយ ដែលនៅពេលនោះអ្នកប្រកាសយ៉ាងឱឡារិកមិនយល់ស្របនឹងពលកម្មកុមារ ហើយពេលនោះអ្នកអញ្ជើញក្រុមយុវជន និងក្មេងៗដែលកំពុងទស្សនាមកជួយបំផ្លាញរូបតំណាងពលកម្មកុមារនេះ ។ ពួកគេថែមទាំងអាចដុតចោលនូវរូបសំណាកនេះ ដើម្បីបង្ហាញអោយឃើញនូវការខឹងសម្បារយ៉ាងខ្លាំងរបស់ពួកគេ ។ ជាការពិតណាស់ ដើម្បីរក្សាសុវត្ថិភាពសកម្មភាពនេះ ត្រូវតែធ្វើដោយមានការគ្រប់គ្រងអោយបានហ្មត់ចត់ !




- ទំនាក់ទំនងជាមួយក្រុមយុវជន និងកុមារក្នុងសហគមន៍ត្រូវតែធ្វើអោយបានកាន់តែច្រើនកាន់តែល្អ ទាំងតាមរយៈសកម្មភាពនៅសាលា ឬនៅសហគមន៍ ។ ជ្រើសរើសថ្ងៃមួយដែលពួកគេអាចចូលរួមបានទាំងអស់គ្នា ហើយមកជួយជុំគ្នាធ្វើជាជួរយ៉ាងវែងនៅកន្លែងសាធារណៈសំខាន់ណាមួយ ជាឧទាហរណ៍ឈរព័ទ្ធជុំវិញសាលារៀន ឬការិយាល័យក្រុមប្រឹក្សាភិបាលមូលដ្ឋាន ។ ជួរនេះជាតំណាងអោយកុមារពលកម្ម ហើយក្រុមយុវជនខ្លះដែលបានចូលរួម អាចកាន់នូវបដាធំៗមួយចំនួន ឧទាហរណ៍បដាដែលមានសរសេរថា "មានកុមារមួយពាន់ដងច្រើនជាងកុមារដែលកំពុងធ្វើពលកម្មនាពេលបច្ចុប្បន្ននេះនៅជុំវិញពិភពលោក" ។ បដាខ្លះទៀត អាចបង្ហាញនូវស្ថិតិសំខាន់ៗអំពីពលកម្មកុមារ ។ ក្រុមមនុស្សឈរជាជួរនេះអាចចល័តទីតាំង និងស្រែកខ្លាំងៗទាក់ទងនឹងពលកម្មកុមារ ដើម្បីទាក់ទាញការចាប់អារម្មណ៍ ពីសហគមន៍ចំពោះការហែរក្បួនរបស់ពួកគេនេះ ។
- អញ្ជើញក្រុមរបស់អ្នកទៅធ្វើទស្សនកិច្ចនៅហាងទំនិញ និងជំនួញនានាក្នុងសហគមន៍ ដើម្បីសួរនាំអ្នកលក់ទាំងនោះ ថាតើពួកគាត់ដឹងដែរឬទេថាទំនិញដែលពួកគេកំពុងដាក់លក់នេះមានប្រើប្រាស់កំលាំងពលកម្មកុមារដោយខុសច្បាប់ដែរឬទេ ។ ពួកគេអាចទទួលបាននូវព័ត៌មានទាំងនេះ តាមរយៈការចុះធ្វើការស្រាវជ្រាវ ឬការជួបជាមួយនឹងមន្ត្រីតំណាងអ្នករកស៊ីនៅក្នុងបរិវេណនោះ ។ គោលបំណងសំខាន់ គឺធ្វើអោយអ្នករកស៊ីវិនិយោគ សហជីព ពាណិជ្ជករ និងសាធារណជនកាន់តែយល់ច្បាស់អំពីបញ្ហានេះហើយ ជួយអោយពួកគេពិចារណាថាតើទំនិញដែលគេទិញ ឬលក់នេះបានធ្វើឡើងយ៉ាងដូចម្តេច ។ ការងារនេះគួរគប្បីធ្វើឡើងតាមសំរួលដោយមិនបង្ខំ និងគ្មានការប្រឈមមុខដាក់គ្នា ។

- វចនាប័ណ្ណប្រៃសណីយ៍ពិសេសមួយ ឧទាហរណ៍អំពី "វិធានការប្រឆាំងការធ្វើពលកម្មកុមារ" ហើយបោះពុម្ពអោយបានកាន់តែច្រើនកាន់តែប្រសើរ ។ ប័ណ្ណប្រៃសណីយ៍នេះគួរតែត្រូវផ្ញើជូនអ្នកនយោបាយថ្នាក់តំបន់ ឬថ្នាក់ជាតិហើយសំណូមពរអោយពួកគេយកចិត្តទុកដាក់ដល់បញ្ហាពលកម្មកុមារ និងចាត់វិធានការដើម្បីលុបបំបាត់វា ។ ពេលនោះក្រុមគួរតែចេញទៅសាលានានានិងសហគមន៍ ហើយជួបប្រជាជនពន្យល់ពួកគាត់អំពីគោលបំណងនៃប័ណ្ណប្រៃណីយ៍នេះ និងសុំអោយពួកគាត់គាំទ្រយុទ្ធនាការនេះផងដោយការជួយចុះហត្ថលេខា និងផ្ញើវាចេញ ។ ប័ណ្ណប្រៃណីយ៍នេះអាចធ្វើនៅលើក្រដាសពណ៌ភ្លឺច្បាស់ ដើម្បីទាក់ទាញអារម្មណ៍អ្នកមើល ឬធ្វើអោយមើលទៅមានភាពរីករាយ និងប្រកបដោយពណ៌ចំរុះ ។ ម្យ៉ាងទៀតអ្នកអាចបង្កើតឡើងនូវប័ណ្ណប្រៃណីយ៍ដ៏ធំមួយ ហើយសុំអោយសមាជិកនៅក្នុងសហគមន៍ចុះហត្ថលេខាលើវា ហើយផ្ញើជូនទៅអ្នកនយោបាយក្នុងតំបន់នេះ ។ គំនិតម្យ៉ាងវិញទៀតគឺធ្វើនូវរូបដ៏ធំមួយ ហើយកាត់វាចំណែកៗជា *Postcard* ដើម្បីផ្ញើចេញទៅ។ អ្នកនយោបាយទាំងនោះអាចប្រមូលប័ណ្ណ *Postcard* ទាំងអស់នោះមកផ្គុំចូលគ្នា ដើម្បីបានយល់ពីអត្ថន័យបង្កប់ក្នុងរូបនោះ ។ ក្រៅពីនេះនៅមានវិធីជាច្រើនយ៉ាងទៀត ដែលមានលក្ខណៈស្រដៀងៗគ្នានេះដែរ ។
- ធ្វើការងារជាក្រុមដើម្បីបង្កើតឡើងនូវប័ណ្ណផ្ទត់ (Leaflet) មួយដែលបង្ហាញអំពីគំរោងការរបស់ពួកគេ និងមានទុកកន្លែងចំហធំមួយ ។ ផ្ញើប័ណ្ណទាំងនេះអោយកូនសិស្សសាលាបឋមសិក្សានៅក្នុងតំបន់ ដើម្បីអោយពួកគេគូររូបពណ៌ចំរុះតាមដែលគេចង់គូរអោយបានយ៉ាងលឿន ដែលបញ្ជាក់អំពីមនោសញ្ចេតនារបស់ពួកគេនៅក្នុងកន្លែងទំនេរនោះផង ។ ក្រុមរបស់អ្នកគួរតែប្រមូលប័ណ្ណទាំងនោះត្រឡប់មកវិញ ហើយបង្កើតការប្រកួតសិល្បៈក្រោមប្រធានបទពលកម្មកុមារឬផ្ញើវាទៅកាន់អ្នកនយោបាយទាំងនោះ ដើម្បីផ្តល់ជាយោបល់អំពីពលកម្មកុមារ ឬលក់វាទៅអោយសហគមន៍មូលដ្ឋាន ដើម្បីប្រមូលប្រាក់សំរាប់គំរោងពលកម្មកុមារ ឬបង្រួមសកម្មភាពទាំង ៣ ខាងលើនេះចូលគ្នាតែម្តង ។
- រៀបចំឡើងនូវទិវាពេលល្ងាចមួយ ដែលនៅពេលនោះក្រុមរបស់អ្នករៀបចំនូវសកម្មភាពជាច្រើនផ្សេងៗទៀត ។ ឧទាហរណ៍ ពួកគេអាចសំដែងនូវឈុតនៃរឿងខ្លីៗដែលគេនិពន្ធដោយផ្ទាល់ក្រោមប្រធានបទពលកម្មកុមារ ។ ពួកគេក៏អាចដាក់តាំងបង្ហាញរូប

គំនូរ រូបចំលាក់ ឬវត្ថុសិល្បៈដទៃទៀតដែលតំណាងអោយពលកម្មកុមារផងដែរ ។ ពួកគេក៏អាចច្រៀងចំរៀងនិពន្ធឡើងដោយពួកគេផ្ទាល់ និងដោយអ្នកដទៃទៀត ឬក៏ដាក់បញ្ចាំងនូវខ្សែភាពយន្តស្តីអំពីរូបនិមិត្តនៃពលកម្មកុមារ ដែលត្រូវបានបំផ្លាញដោយក្រុមយុវជននៃសហគមន៍នោះ ។ ឬម្យ៉ាងទៀត ក្រុមរបស់អ្នកអាចបង្កើតនូវការតាំងពិពណ៌មួយចំនួនស្តីពីពលកម្មកុមារ ឬតំរោងការនេះ ។ អ្នកដែលមានឈ្មោះល្បី ឬអ្នកនយោបាយអាចត្រូវបានអញ្ជើញអោយចូលរួម ដើម្បីបង្កើនការចាប់អារម្មណ៍ខ្លាំងឡើងៗពីសំណាក់សហគមន៍ ។ ម្យ៉ាងវិញទៀតដូចសំណួមពរពីមុនៗដែរ យើងគួរបង្កើត ពិធីដេញថ្លៃវត្ថុសិល្បៈមួយនៅក្រោមប្រធានបទពលកម្មកុមារ ហើយអញ្ជើញអ្នកដែលឆ្នើមប្រចាំតំបន់ ឬជាតិអោយដើរតួជាអ្នកដាក់ដេញថ្លៃវត្ថុទាំងនោះ ។

- បង្កើតឡើងនូវបណ្តាញរបស់ក្រុមយុវជននៅថ្នាក់សហគមន៍ ថ្នាក់តំបន់ ថ្នាក់ជាតិ ឬក៏នៅថ្នាក់អន្តរជាតិ ដោយបង្កើតនូវទំនាក់ទំនងជាមួយសាលារៀននានានៅជុំវិញបញ្ហាពលកម្មកុមារនេះ ។ សាលារៀនគ្រប់ប្រភេទ គ្រប់រូបរាង និងទំហំ ក្លឹបយុវជន ក្លឹបកីឡា និងក្លឹបរបស់សហគមន៍ អាចមានលទ្ធភាពជួយអោយក្រុមយុវជនទាំងនោះអោយធ្វើការរួមគ្នា ដើម្បីជួយដល់កុមារដែលកំពុងធ្វើពលកម្ម ។ លើកទឹកចិត្តដល់ក្រុមរបស់អ្នក អោយសរសេរសំបុត្រទៅកាន់ក្រុមយុវជនផ្សេងៗទៀត បង្កើតទំនាក់ទំនងជាមួយសាលារៀននៅក្រៅប្រទេស ជំរុញអោយសកម្មភាពរួមគ្នានេះមានដំណើរការស្វែងរកការគាំទ្រផ្សព្វផ្សាយជាសាធារណៈអំពីសកម្មភាព ដែលពួកគេកំពុងធ្វើតាមរយៈទស្សនាវដ្តីរបស់សាលារៀន ឬតាមរយៈប្រព័ន្ធផ្សព្វផ្សាយមូលដ្ឋាន ឬបង្កើតអោយមានការផ្លាស់ប្តូរទស្សនកិច្ចគ្នាទៅវិញទៅមក ឬក៏ការបោះជំរុំនារដូវប្រាំង ។ បង្ហាញអោយក្រុមយុវជនទាំងនោះយល់ឃើញថាចំនួនអ្នកចូលរួមកាន់តែច្រើនសំលេងរបស់ពួកគេកាន់តែឮបានខ្លាំង ។

## សកម្មភាពបន្ត

ក្រោយពីបានឆ្លងកាត់សកម្មភាពបង្កើនការយល់ដឹងជាច្រើនកន្លងមក វាមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីអោយក្រុមរបស់អ្នកធ្វើសកម្មភាពអនុវត្តបន្តជាការចាំបាច់នៅក្រោយពេលបញ្ចប់សកម្មភាពទាំងនោះ ។ ជាដំបូងអ្នកគួរតែរៀបចំនូវអត្ថបទព័ត៌មានសំរាប់កាសែតថ្នាក់តំបន់ និងថ្នាក់ជាតិ ។ អត្ថបទនេះគួរតែធ្វើអោយហើយ និង

ធ្វើអោយបានលឿន ពីព្រោះថាប្រព័ន្ធផ្សព្វផ្សាយមានការងាយនឹងភ្លេចខ្លាំងណាស់ ។ អត្ថបទមួយទៀតនៅសប្តាហ៍បន្ទាប់នឹងដាស់រំលឹកដល់សហគមន៍នានាអំពីព្រឹត្តការណ៍ដែលគេបានចូលរួម ។

បន្ទាប់មកទៀតក៏ត្រូវតែសរសេរសំបុត្រថ្លែងអំណរគុណមួយចំនួនធំ ហើយការងារនេះ គួរតែចែកគ្នាធ្វើនៅតាមក្រុម ។ វាគួរត្រូវបានគេផ្ញើទៅអោយអ្នក ដែលបានចូលរួមនៅក្នុងសកម្មភាពនានាប្រចាំថ្ងៃឬសប្តាហ៍ អ្នកដែលបានឧបត្ថម្ភទាំងផ្នែកសេវាឬសំភារៈអ្នក ដែលបានគាំទ្រ និងអ្នកដែលបានចូលរួមព្រឹត្តិការណ៍នានានោះជាដើម ។ វាមានសារៈសំខាន់ណាស់ដែលក្រុមទាំងមូលយល់ថា ត្រូវតែមានការគួរសមចំពោះអ្នកដែលបង្ហាញការគាំទ្ររបស់គេនឹងជួយពង្រឹងការខិតខំប្រឹងប្រែងរបស់ពួកគេ ។ ការធ្វើបែបនេះជាការសំខាន់នៅក្នុងយុទ្ធនាការដែលកំពុងតែធ្វើ ។

ក្រុមគប្បីត្រូវបានលើកទឹកចិត្តអោយសរសេរអំពីបទពិសោធន៍ និងសកម្មភាពរបស់ពួកគេក្នុងការប្រមូលកំលាំងដើម្បីបង្កើតគំរោង ។ ត្រូវចែកក្រុមរបស់អ្នកជាក្រុមតូចៗ ដើម្បីទទួលខុសក្នុងការសរសេរសកម្មភាពផ្សេងៗគ្នា រៀបចំឯកសារសំរាប់សារព័ត៌មាន បង្កើតម៉ូឌុលរូបថត ប្រមូលសំណេរអំពីសិល្បៈ និងអំពីការច្នៃប្រឌិតផ្សេងៗដែលគេបានផ្តល់អោយជាដើម ។ ត្រូវកំណត់ពេលច្បាស់លាស់មួយ ដើម្បីអោយពួកគេបញ្ចប់ការងារនេះ ដូច្នេះពួកគេអាចធ្វើការងារនេះបានចប់នៅមុនពេលដែលគេឈប់ចង់ធ្វើវា ។ ស្នាដៃការងារទាំងនេះគួរតែត្រូវបានរក្សាទុក និងដាក់ឱ្យគេទស្សនានៅក្នុងសហគមន៍នាពេលណាមួយ ។ ក្រុមរបស់យើងគួរគិតផងដែរអំពីការបង្កើតនូវការតាំងពិពណ៌ស្នាដៃនៃការងារទាំងនេះនៅតាមសាលារៀន ឬក៏សហគមន៍ដែលអាចមានរយៈពេលចាប់ពី ១ សប្តាហ៍ឡើងទៅ ដើម្បីអនុញ្ញាតអោយអ្នកចូលទស្សនាស្ងើចសរសើរអំពីទំហំការងារ និងឥទ្ធិពលរបស់គំរោងនេះ ។

## អ្វីដែលត្រូវធ្វើនិងមិនត្រូវធ្វើ

- អ្នកត្រូវដឹងអោយច្បាស់ថា បុគ្គលទាំងអស់គ្នាចូលរួមក្នុងសកម្មភាពបង្កើនការយល់ដឹងនេះ ។ ប្រសិនបើគេពុំបានបង្ហាញការចាប់អារម្មណ៍ ទៅលើសកម្មភាពណាមួយ អ្នកត្រូវណិយាយជាមួយពួកគេ ហើយស្វែងយល់អំពីការងារអ្វីដែលពួកគេចង់ធ្វើ ។ អ្នកត្រូវប្រឹងប្រែងស្វែងយល់អំពីគំនិតរបស់ពួកគេ និងត្រូវធ្វើការងារជាមួយពួកគេដើម្បីអោយយល់អំពីគំនិតនោះ ។




- អ្នកត្រូវព្យាយាមកុំតម្រាប់តាមករណីសិក្សា ដែលបង្ហាញនៅក្នុងម៉ូឌុលនេះ ពីព្រោះវាគ្រាន់តែជាឧទាហរណ៍អំពីអ្វីដែលអាចធ្វើបាន ។ គួរទុកអោយគំនិតស្រមើស្រមៃ និងច្នៃប្រឌិតកើតឡើងដោយឯកឯង ដើម្បីអោយសក្តិសមជាមួយនឹងកាលៈទេសៈ បរិស្ថាន វប្បធម៌ និងប្រពៃណីរបស់អ្នក ។ ករណីសិក្សាមានតួនាទីគ្រាន់តែជាចលករជំរុញអោយអ្នកឆាប់រកឃើញគំនិតនានាដែលមាន និងកំពុងរង់ចាំអ្នក ។
- អ្នកត្រូវប្រើប្រាស់ម៉ាស៊ីនថតវីដេអូ ឬម៉ាស៊ីនថតរូបប្រសិនបើអាចប្រើបាន ។
- អ្នកមិនត្រូវបង្កើតសកម្មភាពទាក់ទាញសហគមន៍ច្រើនពេកទេ ។ ដោយអាស្រ័យទៅលើពេលវេលា ធនធាន និងឧបសគ្គផ្សេងៗទៀត អ្នកគួរជ្រើសរើស និងធ្វើសកម្មភាពតែចំនួនតិចតួចបានហើយ ។ ជ្រើសរើសសកម្មភាពទាំងឡាយណាដែលសក្តិសមនឹងតំរូវការ និងការលៈទេសៈរបស់ក្រុម ។
- ត្រូវបង្កអោយមានការសប្បាយនៅក្នុងក្រុម ដើម្បីជួយការបង្រៀន និងធ្វើលំហាត់ ។
- ត្រូវអនុញ្ញាតអោយក្រុមទាំងមូលសំរេចចិត្តថានឹងធ្វើអ្វី ហើយទទួលការខុសត្រូវតាមកំរិតផ្សេងៗគ្នារបស់ពួកគេ ។ ព្យាយាមកុំបង្ខំអ្នករាល់គ្នា ឬក្រុមទាំងមូលអោយទទួលយកអ្វីៗតាមការចង់បានរបស់អ្នក ។ ការឈានទៅដល់សហគមន៍គឺដាច់ខាតត្រូវតែមានការចូលរួមពីអ្នកដទៃ ។
- ត្រូវព្យាយាមកុំអោយមានការតិះទៀន ឬចំអកដាក់គ្នានៅក្នុងក្រុម ។ ត្រូវសង្កត់ធ្ងន់លើភាពវិជ្ជមានក្នុងបញ្ហានីមួយៗ ។
- ត្រូវអនុញ្ញាតអោយមានការនិយាយលេងសើច ការសន្ទនាខ្លីៗ ការបញ្ឆិតបញ្ឆៀងគ្នា ការនិយាយរឿងកំប្លែង និងការប្រកួតប្រជែងគ្នាក្នុងករណីដែលវាអាចគ្រប់គ្រងបាន ។
- ត្រូវយកសមិទ្ធផលពីមេរៀនមុនៗ ដូចជាតែងសេចក្តី រូបចំលាក់ គំនូរ កំណាព្យ រឿង និងរូបថតជាដើមមកតុបតែងបន្ទប់ដែលសមាជិករបស់សហគមន៍នឹងមកជួបជុំគ្នា ឧទាហរណ៍ ដូចជាបន្ទប់ទទួលភ្ញៀវដែលនៅក្នុងនោះមានការសំដែងសិល្បៈបន្ទប់ដែលដាក់ការតាំងពិពណ៌ ឬក៏ទីលានកីឡាដែលត្រូវបានគេរៀបចំ ។
- ត្រូវដឹងច្បាស់ថាសកម្មភាពនានារបស់សហគមន៍ ឬក៏ថ្នាក់រៀននានាត្រូវបានគេលើកយកមកពិភាក្សាយ៉ាងផុសផុល ។
- ត្រូវដឹងច្បាស់ថាសកម្មភាពទាំងនេះត្រូវបានកត់ត្រាទុក និងត្រូវបានគេអនុវត្តបន្តទៅទៀត ។



- ត្រូវអោយក្រុមទាំងមូលសរសេរសំបុត្រថ្លែងអំណរគុណចំពោះអ្នកគ្រប់រូបដែលបានចូលរួមនៅក្នុងសកម្មភាព ឬក៏ព្រឹត្តិការណ៍ទាំងនេះ ។ ត្រូវសង្កត់ធ្ងន់ទៅលើឥទ្ធិពលនៃទំនាក់ទំនងល្អរបស់សហគមន៍ ។
- ត្រូវព្យាយាមកុំធ្វើអោយក្មេងៗស្ថិតនៅក្នុងស្ថានភាពមួយ ដែលជំនឿទុកចិត្តរបស់ពួកគេត្រូវបំផ្លាញ ប្រសិនបើពួកគេ ឬពួកនាងមិនអាចហាត់ធ្វើការអនុវត្តបានដូចជាបង្រៀន រៀន មានផ្សេងទៀត ឬសំដែងសិល្បៈ ជាសាធារណៈ ជាដើម ។ រាល់សមាជិកទាំងឡាយគួរតែមានតួនាទីរបស់ខ្លួននៅក្នុងសកម្មភាពទាំងនេះ ។ អ្នកគួរតែគាំទ្រទង្វើបែបនេះ និងគួរដឹងអោយច្បាស់ថាក្មេងៗទាំងនោះពេញចិត្តនឹងតួនាទីរបស់ពួកគេ ។
- ត្រូវដឹងច្បាស់ថា គ្រប់សមាជិកទាំងអស់ចូលរួមក្នុងការសរសេរសំបុត្រ ពីព្រោះវាអាចជួយអោយពួកគេមានការរីកចំរើនខាងជំនាញផ្ទាល់ខ្លួន ជំនាញសង្គម និងជំនាញទំនាក់ទំនងរបស់ពួកគេ ។
- កុំធ្វើអោយសហគមន៍ធ្លាក់ចូលក្នុងការប្រកួតប្រជែង ។
- ត្រូវបង្កើតអោយមានការសួរដេញដោលដោយម៉ត់ចត់មួយក្រោយពីសកម្មភាពសមាហរណកម្មសហគមន៍ ។ វាមានសារៈសំខាន់ណាស់សំរាប់ក្រុមរបស់អ្នក ដែលត្រូវបានអនុញ្ញាតអោយបញ្ចេញគំនិតរបស់ពួកគេយ៉ាងពេញលេញ និងដោយចំហបន្ទាប់ពីការធ្វើលំហាត់មក ។ ពួកគេនឹងមានគំនិតច្រើន បន្ទាប់ពីសកម្មភាពទាំងនោះ ពួកគេត្រូវបានអនុញ្ញាតអោយលើកឡើងនូវអារម្មណ៍រៀងៗខ្លួន ដែលគេមានទៅលើសុវត្ថិភាពរបស់ក្រុម ។ លំហាត់នេះនឹងធ្វើអោយអ្នកយល់ពីប្រតិកម្ម និងការគិតរបស់ពួកគេ ហើយស្វែងយល់ថា តើនៅជំហានបន្ទាប់នេះគួរធ្វើអ្វីក្នុងករណីដែលមានការព្រួយបារម្ភមែន ។

## ការពិភាក្សាបញ្ចប់

*បង្រៀនមួយពេល*

នៅពេលដែលបានបញ្ចប់សកម្មភាពអភិវឌ្ឍន៍សហគមន៍ អ្នកប្រមូលសមាជិកទាំងអស់អោយជួបជុំគ្នានៅក្នុងបន្ទប់ប្រជុំ ឬថ្នាក់រៀនដូចធម្មតា ហើយត្រូវដឹងថាបរិយាកាសពេលនោះប្រាកដជាធូរស្រាល និងសប្បាយរីករាយ ។ យើងអាចអញ្ជើញមនុស្សខាងក្រៅ ដែលធ្លាប់ពឹងអោយចូលរួមផងដែរ យើងណិយាយអំពីសកម្ម

ភាព ដែលក្រុមបានធ្វើ និងជំរុញអោយមានការពិភាក្សាជាទូទៅមួយ អំពីសកម្មភាពនោះ ។ ចូរស្វែងយល់អំពីអ្វីដែលពួកគេចូលចិត្តខ្លាំងជាងគេ ហើយអ្វីដែលពួកគេមិនសូវចង់ ។ ត្រូវអនុញ្ញាតអោយគេនិយាយដោយសេរី និងចំហអំពីបញ្ហាដែលទាក់ទង នឹងការពិភាក្សា ។ ជាធម្មតាការផ្តល់សេរីភាពដល់ពួកគេក្នុងការនិយាយ និងលើកឡើងនូវអារម្មណ៍រៀងៗខ្លួនអំពីគំរោងនេះ ដោយហេតុថាដំណើរការរបស់វាអាចបណ្តុះជំនឿទុកចិត្ត និងបង្កើតអោយមានទំនាក់ទំនងយ៉ាងស្អិតល្មួតមួយក្នុងក្រុមទាំងមូល ។

ប្រសិនបើអ្នកមានរូបភាពវីដេអូ ស្តីអំពីរាល់សកម្មភាព ជាពិសេសការសំដែងនានានោះ អ្នកត្រូវបញ្ចាំងវាអោយក្រុមទាំងមូលទស្សនា ។ ការបញ្ចាំងនេះ មានគោលបំណង ២: ទី ១ ធ្វើអោយក្រុមទាំងមូលមានការសប្បាយរីករាយ ដោយពួកគេសើចខ្លួនឯងនិងអ្នកដទៃ ហើយទី ២ បង្ហាញអំពីការសំដែងរបស់ពួកគេ នៅចំពោះមុខទស្សនិកជនជាច្រើន ។ ពួកគេនឹងយល់កាន់តែច្បាស់ថែមទៀតនូវឥទ្ធិពលនៃសកម្មភាពដែលគេបានធ្វើ និងមូលហេតុដែលមនុស្សម្នាមានប្រតិកម្មចំពោះអ្វីដែលពួកគេបានធ្វើ ។ នេះគឺជាពេលវេលាដ៏អស្ចារ្យមួយនៃគំរោង ។ ចូរអ្នកលើកទឹកចិត្តពួកគេអោយរៀបរាប់អំពីអ្វីដែលពួកគេបានឃើញ ។ តើពួកគេនឹងធ្វើអ្វីផ្សេងៗទៀតឬទេ ? តើពួកគេយល់ថា ពួកគេមានឥទ្ធិពលលើសហគមន៍ដែរឬទេ ? តើសកម្មភាពទាំងនេះស្តែងចេញមកអោយឃើញដោយរបៀបណា ? តើពួកគេគិតថាគេបានទទួលការគាំទ្រមួយដ៏ល្អដែរឬទេ ? តើឥឡូវនោះ ពួកគេអាចធ្វើអ្វីទៀត ដើម្បីអោយមានការគាំទ្រខ្លាំង ?



ចូរអ្នកពិនិត្យមើលរបាយការណ៍ និងអត្ថបទដែលគេបានសរសេរ ។ តើក្រុមមានប្រតិកម្មយ៉ាងណាចំពោះរបាយការណ៍ និងអត្ថបទនេះ ? ចូរអនុញ្ញាតអោយពួកគេបញ្ចេញគំនិតរៀងៗខ្លួនលើរបាយការណ៍នោះ ។ សួរពួកគេថា តើពួកគេរីករាយជាមួយនឹងសកម្មភាពអនុវត្តបន្តដែរឬទេ ? តើពួកគេអាចនឹងឃើញនូវសកម្មភាពបន្ត ដែលមានប្រសិទ្ធភាពផ្សេងៗទៀតដែរឬទេ ?

ចុងបញ្ចប់នេះ ការពិនិត្យអំពីការប្រឹងប្រែងរបស់ពួកគេទាំងអស់តាមគំរូនៃយុទ្ធនាការពិភពលោក ដើម្បីលុបបំបាត់ពលកម្មកុមារ គឺជាការសំខាន់សំរាប់ក្រុម ។ អ្វីដែលពួកគេបានធ្វើនឹងនាំមកនូវភាពសប្បាយរីករាយ ហើយពួកគេនឹងត្រូវបានជ្រើសរើសអោយចូលរួមសកម្មភាពជាបន្តទៅទៀត ។ ការអនុញ្ញាតអោយពួកគេពិចារណាអំពីសភាពនៃកុមារពលករនឹងទុកពេលវេលាខ្លះ ដើម្បីអោយពួកគេជញ្ជឹងគិតអំពីការ

ជិះជាន់លើកំលាំងពលកម្មកុមារមិននាំមកនូវអ្វីដែលមិនល្អឡើយ ។ អោយពួកគេពិចារណាពីអារម្មណ៍របស់ពួកគេ ពេលដែលពួកគេបានជួយរកមូលហេតុនៃពលកម្មកុមារតាមរយៈសកម្មភាពនានារបស់ពួកគេ ។ តើពួកគេអាចប្រមូលថវិកាសំរាប់ការជួយនេះបានខ្លះ ឬទេ ? ប្រសិនបើបានតើពួកគេគិតប្រើប្រាស់ថវិកានោះដូចម្តេច ដើម្បីជួយកុមាររងគ្រោះទាំងនោះ ? តើពួកគេគិតឃើញនូវគំនិតផ្សេងៗទៀតឬទេ ? តើពួកគេគិតថានឹងមានអ្វីកើតឡើងនាពេលបច្ចុប្បន្ននេះ? តើពួកគេមានការពេញចិត្តនឹងអ្វីដែលពួកគេបានធ្វើដែរឬទេ ? តើពួកគេចង់សាកល្បង និងបន្តធ្វើសកម្មភាពទៀតដែរឬទេ ? តើពួកគេគិតថាពួកគេនឹងអនុវត្តមេរៀននៃគំរោងនេះជារៀងរហូតដែរឬទេ? ហើយអាចបន្តការផ្សព្វផ្សាយទៅដល់អ្នកដទៃទៀតដែរឬទេ ? តើពួកគេអាចយល់បានថែមទៀតដែរឬទេអំពីអំពើការរំលោភសិទ្ធិ និងជិះជាន់កំលាំងលើកុមារ ?

ប្រើប្រាស់ពេលវេលាចុងក្រោយនេះសំរាប់អោយបុគ្គល និងសមូហភាពពិចារណាអំពីគំរោងទាំងមូលក៏ដូចជាគំនិតរបស់ក្រុម និងតំលៃរបស់គំរោងនោះចំពោះបុគ្គលក៏ដូចជាចំពោះសមូហភាព ។

## ការវាយតំលៃនិងសកម្មភាពបន្ត

កត្តាដែលអាចអោយធ្វើសកម្មភាពអភិវឌ្ឍន៍សហគមន៍មានច្រើនហើយប្លែកៗពីគ្នា ។ លទ្ធផលដែលទទួលបានរួមមាន:

- គំនិតអ្វីខ្លះដែលបានរីកចំរើន
- សកម្មភាពអ្វីខ្លះដែលត្រូវបានអនុវត្ត
- ការអនុវត្តបន្តអ្វីខ្លះដែលបានធ្វើ
- ពង្រីកការចូលរួមនៃសហគមន៍នានា
- កំរិតនៃការលើកកំពស់ការយល់ដឹងនៅក្នុងសហគមន៍នានា
- ការផ្សព្វផ្សាយអំពីសកម្មភាពទាំងនោះ



ជាការពិតណាស់ វាមានកត្តាជាច្រើនទៀត ប៉ុន្តែប្រសិនបើកត្តាខាងលើនេះកើតមានឡើងមែននោះ ក្រុមនឹងធ្វើសកម្មភាពបានយ៉ាងល្អហើយអ្នកគួរតែប្រាប់ពួកគេយ៉ាងដូច្នេះដែរ ។ សកម្មភាពលើកកំពស់ការយល់ដឹងដូច ដែលបានរៀបរាប់នៅក្នុងករណីសិក្សាអាចអោយក្រុមយុវជនមានការចាប់អារម្មណ៍ និងមានភាពរីករាយ ។

វាថែមទាំងជួយពង្រឹងគោលបំណង និងគោលដៅនៃម៉ូឌុលទាំងនេះ ហើយអាចនឹងមានឥទ្ធិពលយ៉ាងខ្លាំងទៅលើសហគមន៍ ដែលមានទំនាក់ទំនងជាមួយនឹងក្រុមខាងលើនេះ ។

ម៉ូឌុលសិក្សានេះ គួរតែជាម៉ូឌុលចុងក្រោយដែលក្រុមរបស់អ្នក នឹងយកទៅអនុវត្ត ។ វាប្រាកដជាមានការកត់សំគាល់ខ្ពស់ទៅលើចុងបញ្ចប់របស់វា ។ វាផ្តល់ឱកាសដល់ក្រុមដើម្បីអោយចំណេះដឹង ជំនាញ និងបទពិសោធន៍ ដែលពួកគេបានបង្កើតតាមរយៈគំរោងនេះអោយក្លាយទៅជាសកម្មភាពពិត ។ វាជួយអោយអ្នកយល់អំពីតំលៃនៃការងារដែលអ្នកបានធ្វើ ហើយវាជាការសាកល្បងចុងក្រោយបង្អស់ដែលបង្ហាញអោយឃើញជោគជ័យរបស់វា ដោយសារទំរង់នៃគរុកោសល្យដែលត្រូវបានកសាងសំរាប់ក្រុមផ្សេងៗ និងដើម្បីជួយក្រុមយុវជនអោយក្លាយទៅជាភ្នាក់ងារនៃការបង្រួបបង្រួម និងផ្លាស់ប្តូរសង្គម ។ ការពាំនាំនូវសារនេះទៅកាន់សហគមន៍ធំៗបានទទួលជោគជ័យយ៉ាងណានោះ គឺជាការឆ្លុះបញ្ចាំងអំពីឥទ្ធិពលនៃម៉ូឌុលទាំងនេះអំពីការងាររបស់អ្នក និងអំពីក្រុមយុវជន ។ គេជឿជាក់ថា លទ្ធផលរួមនៃសៀវភៅនេះ និងម៉ូឌុលដទៃទៀតនឹងមិនត្រឹមតែជួយកែលំអអាកប្បកិរិយា និងឥរិយាបថយុវជននៅក្នុងក្រុមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសមាជិកនានានៃសហគមន៍ធំៗផងដែរ ។

## ឧបសម្ព័ន្ធ ១

## ករណីសិក្សា ៖ ការអភិវឌ្ឍន៍សហគមន៍នៃសាធារណរដ្ឋអៀរឡង់

ដោយសារតែវាអាចមានវិធីផ្សេងៗគ្នាដែលគេអាចបង្កើតបាននៅក្នុងប្រទេស និងកន្លែងមួយចំនួននោះ យើងក៏បានលើកបង្ហាញនូវឧទាហរណ៍អំពីលំហាត់នៃការអភិវឌ្ឍន៍សហគមន៍ ក្នុងដំណាក់កាលសាកល្បងរបស់ម៉ូឌុលសិក្សាទាំងនេះនៅសាធារណរដ្ឋអៀរឡង់ ។ សាធារណជនត្រូវបានផ្តល់ព័ត៌មានអំពីដំណើរ រីកចំរើនចាប់តាំងពីការចាប់ផ្តើមគំរោងមកម៉្លេះ ។ អត្ថបទព័ត៌មានមួយចំនួនត្រូវបានផ្សព្វផ្សាយនៅលើទំព័រកាសែត និងព្រឹត្តិបត្រព័ត៌មានក្នុងតំបន់ រីឯបទសម្ភាសន៍ត្រូវបានចាក់ផ្សាយតាមវិទ្យុនៅក្នុងតំបន់ផងដែរ ។ នេះជាផ្នែកមួយនៃដំណើរការអប់រំសិស្សទាំងឡាយបានស្រាវជ្រាវអំពីប្រធានបទនេះតាមប្រព័ន្ធអ៊ីនធើណែត ធ្វើការសម្ភាសន៍ជាមួយអ្នកនយោបាយនានានៅក្នុងតំបន់ និងបានសរសេរជាលិខិតផ្ញើជូនរដ្ឋាភិបាល និងតំណាងអាជ្ញាធរប្រចាំតំបន់ សមាគមពាណិជ្ជកម្ម និងអង្គការក្រៅរដ្ឋាភិបាល និងឥស្សរជននានាផ្សេងៗទៀត ។

ពួកគេបានបង្កើតឡើងនូវ "ជ្រុងមួយនៃពលកម្មកុមារ" នៅបណ្ណាល័យក្នុងតំបន់មួយតុបតែងលំអដោយប័ណ្ណប្រកាស និងរក្សាទុកម៉ូឌុល និងម៉ូឌុលស្តើងៗជាច្រើនក្បាលណិយាយអំពីពលកម្មកុមារ និងអំពីបញ្ហាផ្សេងៗ ដែលទាក់ទងនឹងពលកម្មកុមារ ។ សំភារៈទាំងនេះត្រូវបានគេប្រទះឃើញអាចអោយគេស្រាវជ្រាវ និងផ្តល់អោយដោយបណ្ណាល័យ ។ ការធ្វើបែបនេះអាចអោយក្រុមយុវជន និងសមាជិកនានានៃសហគមន៍ ដែលមានការចាប់អារម្មណ៍លើពលកម្មកុមារអានម៉ូឌុលពីបញ្ហានេះ និងស្វែងយល់ពីបញ្ហានានាដែលទាក់ទងនឹងបញ្ហានេះដែរ ។ ដូច្នេះការអាននេះ អាចពង្រីកទស្សនៈរបស់គេ ហើយគាំទ្រដល់ការងារក្នុងម៉ូឌុល ស្តីពីការស្រាវជ្រាវ និងព័ត៌មានផងដែរ ។ ពួកគេបានធ្វើការជជែកតទល់គ្នាក្រោមប្រធានបទ "កុមារជាកម្មសិទ្ធិ របស់សាលារៀន ពុំមែនជារបស់កន្លែងធ្វើការទេ" នៅចំពោះសមាជិកក្រុមប្រឹក្សាភិបាលមូលដ្ឋាន ។ ពួកគេបានរៀបចំ ការប្រកួតប្រជែងផ្ទាំងរូបភាពមួយក្រោមប្រធានបទ SCREAM និងបានជួយវិនិច្ឆ័យលទ្ធផលការប្រកួត នោះទៀតផង ។ ពួកគេបានរៀបចំពិធីរាំកំសាន្ត Disco មួយ ដើម្បីស្វែងរកប្រាក់ឧបត្ថម្ភជួយដល់កុមាររងគ្រោះដោយពលកម្មនៅប្រទេសនេប៉ាល់អោយបានប្រសើរឡើងវិញ ។ ពួកគេបានធ្វើការជាមួយនឹងអ្នកនិពន្ធនៅក្នុងតំបន់ដើម្បីច្នៃប្រឌិតសរសេរអត្ថបទណាមួយ និងសហការជាមួយសិល្បករក្នុងស្រុកដើម្បីដេរភួយសំឡីដោយមានគូររូបលើវាក្រោមប្រធានបទពលកម្មកុមារ ។

លើសពីនេះទៀត ពួកយុវជនទាំងនេះបានធ្វើការជាមួយក្រុមល្ខោនអាជីពនៅក្នុងស្រុកដើម្បីផលិតរឿងរបស់ពួកគេអំពីពលកម្មកុមារ ។ ការសំដែងនេះបានធ្វើការកត់សំគាល់លើសិស្ស ដែលបានចូលរួមសំដែង និងបុគ្គលិកសិក្សានៃសាលារៀននោះ ។ ទោះជាយ៉ាងណាក៏ដោយ ការសំដែងតែឯងនេះមិនអាចបង្កើន

ការយល់ដឹងរបស់សហគមន៍ អោយបានគ្រប់គ្រាន់តាមបំណងនោះទេ ហើយក៏មិនអាច អោយក្រុមយុវជន យកអ្វីដែលពួកគេបានរៀននៅក្នុងម៉ូឌុលទៅផ្សព្វផ្សាយបានទូលំទូលាយផងទេ ។ នៅពេលដែលការយល់ដឹងត្រូវបានបង្កើននៅក្នុងចំណោមក្រុមយុវជន ហើយគំនិតច្នៃប្រឌិត និងកំលាំងរបស់ ពួកគេត្រូវបានបង្កើនឡើងដែរនោះ យើងមានអារម្មណ៍ថា ការផ្តល់អោយពួកគេបានបង្ហាញពីអារម្មណ៍ និង បំណងថ្មីរបស់ពួកគេមានសារៈសំខាន់ណាស់ ។ លើសពីនេះទៀត ក្រុមសំរបសំរួលគំរោងនេះបានគិតថា ជ័យជំនះនៃដំណាក់កាលសាកល្បងនេះបានមកពីសហគមន៍ទាំងមូល ហើយជាពិសេសបានមកពីអ្នកអប់រំអ្នក ធ្វើការសំរេចចិត្ត និងអ្នកដែលបានរួមចំណែកទាំងនៅក្នុង និងនៅក្រៅប្រទេសក្នុងបំណងចង់បង្ហាញដល់ពួក គេពីអ្វីដែលក្រុមយុវជនអាចធ្វើបាន ដើម្បីលើកទឹកចិត្តជំរុញប្រឹងប្រែងការគាំទ្រវិធីសាស្ត្រគរុកោសល្យរបស់ពួកគេ ។

ដូចដែលបានបញ្ជាក់នៅក្នុងម៉ូឌុលណែនាំ អ្នកប្រើប្រាស់រួចហើយ អ្នកអប់រំនិងក្រុមរបស់ពួកគេគួរតែមានមហិច្ឆតាធំ ។ ប្រសិនបើអ្នកអប់រំពុំមានមហិច្ឆតា និងមិនប្រកួតប្រជែងគ្នានោះទេ នៅពេលនោះដំណើរការនេះនឹងមិនអាចសំរេចដល់កំរិតអតិបរិមារបស់វាបានទេ ។ បទពិសោធន៍បានបង្ហាញថា ក្រុមយុវជនមានសមត្ថភាពគ្រប់គ្រាន់បំពេញបានភាពច្រើននូវមហិច្ឆតារបស់ពួកគេប្រសិនបើពួកគេដឹងថាពួកគេត្រូវបានគាំទ្រ និងផ្តល់ទំនុកចិត្តនោះ ។

ដូច្នេះ នៅក្នុងករណីសិក្សាដែលពាក់ព័ន្ធនេះ អ្នកអប់រំបានពិភាក្សាអំពីបញ្ហាទាក់ទងរបស់សហគមន៍ធំជាមួយនឹងក្រុមរបស់អ្នក ។ ដោយផ្អែកទៅលើការពិភាក្សាជាមូលដ្ឋាននេះ គេបានសំរេចចិត្តបង្កើត និងដឹកនាំសកម្មភាពសប្តាហ៍បង្កើនការយល់ដឹង និងបញ្ចប់ដោយការសំដែងរឿងរបស់ពួកគេនៅក្នុងអាគារស្នាក់ការភូមិមួយដោយអញ្ជើញសហគមន៍ធំៗអោយចូលរួមនិងទស្សនា ។

## សប្តាហ៍បង្កើនការយល់ដឹង

ក្រុមទាំងមូលត្រូវបានអនុញ្ញាតអោយបញ្ចេញជាយោបល់អំពីសកម្មភាពណាខ្លះ ដែលអាចរៀបចំឡើងសំរាប់សកម្មភាពសប្តាហ៍បង្កើនការយល់ដឹងនេះ ហើយកម្មវិធីការងារត្រូវបានបង្កើនឡើងដូចមានខាងក្រោមនេះ :

### *ប្រព័ន្ធផ្សព្វផ្សាយ*

ទំរង់ ៣ នៃប្រព័ន្ធផ្សព្វផ្សាយត្រូវបានគេកំណត់ថា ជាមធ្យោបាយសំរាប់ពាំនាំនូវសារនេះទៅកាន់សហគមន៍ខាងក្រៅមាន : ប័ណ្ណព័តិមានសំរាប់បរិស័ទនៅតាមព្រះវិហារ សំណើសំរាប់ប្រព័ន្ធផ្សព្វ ផ្សាយ និងវិទ្យុ ។

- **ព្រះវិហារ**

នៅប្រទេសអៀរឡង់ ព្រះវិហារកាតូលិកនៅតែដើរតួនាទីសំខាន់នៅក្នុងសហគមន៍ ជាពិសេសនៅក្នុងសហគមន៍ជនបទនានា និងនៅក្នុងប្រទេសទាំងមូល ។ បរិស័ទព្រះវិហារនីមួយៗបានបង្កើតនូវព្រឹត្តប័ត្រព័ត៌មានមួយដែលនៅក្នុងនោះលោកអាចារ្យនៅក្នុងតំបន់នោះបានដាក់បញ្ចូលនូវការផ្សព្វផ្សាយអំពីព្រឹត្តការណ៍នានានៃសប្តាហ៍បង្កើនការយល់ដឹង ។ បន្ថែមពីលើនេះទៀត លោកអាចារ្យខ្លះអាចធ្វើការប្រកាសអំពីកម្មវិធីទាំងនេះ នៅចុងបញ្ចប់នៃពិធីបុណ្យរបស់ព្រះវិហារនីមួយៗ ។

- **កាសែតតំបន់**

អត្ថបទសារព័ត៌មានអំពីពលកម្មកុមារ និងគំរោងរបស់វាត្រូវបានគេបោះពុម្ពនៅលើទំព័រនៃកាសែតនៅក្នុងតំបន់មួយសប្តាហ៍មុនសកម្មភាពខាងលើ ។ លើសពីនេះទៀត ការផ្សាយពាណិជ្ជកម្មដែលបានជួយរចនាឡើង ដោយអ្នកជំនាញរចនាក្រាហ្វិក ត្រូវបានដាក់អោយមានដំណើរការជួយផ្សព្វផ្សាយសកម្មភាពទាំងអស់របស់សប្តាហ៍ ។ អត្ថបទសំណេរត្រូវធ្វើមុនសកម្មភាពរបស់សប្តាហ៍បង្កើនការយល់ដឹងនេះ អត្ថបទមួយចំនួនក៏ត្រូវបានផ្សព្វផ្សាយផងដែរនៅក្រោយព្រឹត្តិការណ៍នោះ ។

- **ស្ថានីយ៍វិទ្យុមូលដ្ឋាន**

ការផ្សាយពាណិជ្ជកម្មពិសេសមួយតាមវិទ្យុ ដែលមានការចូលរួមពីសិស្សមួយចំនួនផងដែរនោះ ត្រូវបានផ្សាយចំនួន ៥ ថ្ងៃក្នុងពេលពង្រឹងការងារនៃសប្តាហ៍បង្កើនការយល់ដឹងនេះ ។ សំលេងរបស់ពួកគេបានប្រាប់ពីតួលេខនានានៃពលកម្មកុមារ និងបញ្ជាក់ថាពលកម្មកុមារនៅតែមានជាបន្តទៅទៀតដោយសារតែការមិនយកចិត្តទុកដាក់របស់សង្គមចំពោះជោគវាសនាកុមារជាច្រើនលាននាក់នោះ ។

## ***ការអប់រំដោយក្រុមដែលមានអាយុស្របគ្នា***

ការអប់រំយុវជនដោយក្រុមយុវជនដូចគ្នាជានិច្ចកាលមានឥទ្ធិពល ហើយមានប្រសិទ្ធភាពជាងការងារដែលក្រុមមនុស្សពេញវ័យធ្វើ ។ ជាទូទៅនៅក្នុងករណីសិក្សានេះ សមាជិកទាំងឡាយនៅក្នុងក្រុមត្រូវបានផ្តល់ឱកាសដើម្បីអនុវត្តមេរៀនមួយនៃមេរៀនទាំងនេះ ហើយនឹងក្លាយជា "គ្រូ" រយៈពេល ១ ថ្ងៃ ។

ម៉ោងសិក្សាត្រូវបានរៀបចំក្រោយការជួបពិភាក្សាគ្នាជាមួយនាយកសាលាបឋមសិក្សាចំនួន ២ នៅក្នុងតំបន់ ។ ថ្នាក់រៀនដែលមានកូនសិស្សអាយុ ១១ ឬ ១២ ឆ្នាំ ចំនួន ២ ត្រូវបានប្រើប្រាស់រយៈពេល ៩0 នាទី ។

សៀវភៅដែលត្រូវជ្រើសរើសសំរាប់សិក្សាគឺម៉ូឌុលរូប (Collage) ។ នេះគឺជាម៉ូឌុលដ៏ល្អមួយដែលសក្តិសមជាមួយនឹងក្មេងតូចៗ ។ សមាជិកនីមួយៗត្រូវបានផ្តល់ជូននូវឯកសារចំលង ១ ច្បាប់ ពីសៀវ

ភៅនោះ ដើម្បីយកទៅសិក្សាអោយបាន ២ ឬ ៣ ថ្ងៃមុន ដើម្បីរៀបចំការបង្រៀនជាមុន ។ ក្នុងករណីនីមួយៗសមាជិកម្នាក់ធ្វើជាអ្នកត្រួតពិនិត្យដំណើរការនេះ ហើយសមាជិកដទៃទៀតជួយកុមារទាំងនោះក្នុងការរៀបចំរូបភាពរបស់ពួកគេ ។ មុនពេលចាប់ផ្តើមមេរៀន ក្រុមរបស់គេបានធ្វើការបង្ហាញខ្លួនអោយស្គាល់គ្នាទៅវិញទៅមក ហើយបានរៀនរាប់អំពីគំរោងរបស់ពួកគេ និងបើកអោយមានសំនួរ និងចំលើយអំពីបញ្ហាពលកម្មកុមារ ។ ពួកគេបានបែងចែកថ្នាក់រៀនទាំងមូលជាក្រុមតូចៗ ហើយពិនិត្យមើលថ្នាក់តើសំភារៈសំរាប់បង្រៀននោះវាគ្រប់គ្រាន់ដែរឬទេ ។ នៅពេលដែលរូបភាពនីមួយៗត្រូវបានរៀបចំរួច រូបភាពទាំងនោះត្រូវព្យួរ និងដាក់អោយមើល នៅតាមជញ្ជាំងនៃថ្នាក់រៀន ហើយក្រុមដទៃទៀតជាអ្នកទាយចំណេះដឹងរបស់វា ។ ពេលដែលគេមើលដល់រូបភាពដែលមានអក្សរសរសេរអំពីពលកម្មកុមារក្រុម ដែលផលិតវានោះត្រូវបានសួរអោយពន្យល់អំពីរូបភាពនេះនិងមូលហេតុដែលគេប្រើប្រាស់រូបភាពបែបនោះ ។ ការងារទាំងនោះត្រូវបានរក្សាទុក និងដាក់តាំងអោយគេទស្សនា នៅវេលារាត្រីវប្បធម៌ពិសេសមួយនាពេលបញ្ចប់ "សកម្មភាពសប្តាហ៍នេះ" ។

គ្រប់សកម្មភាពទាំងអស់ក្នុងសប្តាហ៍នោះ គឺជាការងារតែមួយគត់ដែលបង្ហាញអោយឃើញច្បាស់ថា តើគំរោងនេះទទួលបានលទ្ធផលដល់កំរិតណា តើក្រុមរបស់គេមានឥទ្ធិពលបែបណា និងតើមេរៀននេះមានសារៈសំខាន់ និងមានលក្ខណៈទូលំទូលាយបែបណា ។ សកម្មភាពនេះបានផ្តល់នូវទំនុកចិត្តយ៉ាងខ្លាំងដល់អ្នកដែលបានចូលរួមក្នុងលំហាត់នេះផងដែរ ។

## ការពិភាក្សាតុមូល

ការពិភាក្សាតុមូលជាសាធារណៈមួយត្រូវបានរៀបចំឡើងក្រោមប្រធានបទ"ពីកន្លែងធ្វើការមកការស៊ីឈ្នួលរបស់ពលកម្មកុមារនាសម័យអតីតកាលនៅតំបន់ **East Clare**" (East Clare គឺជាតំបន់មួយដែលស្ថិតនៅតំបន់ ឆ្នេរភាគខាងលិច នៃប្រទេសអៀរឡង់ជាកន្លែងដែលគេសាកល្បងគំរោងនេះ) ។

ទោះបីជាប្រទេសអៀរឡង់នាពេលបច្ចុប្បន្ននេះជាប្រទេសរីកចំរើន និងមានការអភិវឌ្ឍន៍ក៏ដោយ ក៏កាលពីរយៈកន្លងទៅថ្មីៗប្រទេសនេះគឺជាប្រទេសក្រីក្រមួយ និងញាំញីរីខានឥតឈប់ឈរដោយសារបញ្ហានយោបាយ និងបញ្ហាសេដ្ឋកិច្ចសង្គមដែលធ្វើអោយប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនជួបទុក្ខនានាពេលបច្ចុប្បន្ននេះ ។ នៅតែមានប្រជាជនមួយចំនួនកំពុងរស់នៅឯតំបន់នោះ ហើយអាចនិទានប្រាប់អំពីប្រវត្តិនៃការធ្វើជាទាសករកាលពីពួកគេនៅកុមារភាព ។ ទំលាប់មួយដែលគេធ្លាប់បានអនុវត្តនៅតំបន់ជនបទនៃប្រទេសអៀរឡង់គឺការស៊ីឈ្នួល ដែលពេលនោះក្រុមកសិករបានស្វែងរកកំលាំងពលកម្មដែលមានតំលៃថោកនាពេលរដូវច្រូតកាត់មកដល់ ។ ក្រុមកុមារធ្វើពលកម្មទាំងនោះត្រូវបានផ្តល់នូវការស្នាក់នៅ និងចំណីអាហារ ហើយផ្តល់អោយពួកគេនូវប្រាក់ឈ្នួលចំនួន តិចតួចដើម្បីត្រឡប់ ទៅរកក្រុមគ្រួសារគេវិញ ។

ដើម្បីបង្កើនអោយមានទំនាក់ទំនងរវាងប្រទេសអៀរឡង់ពីអតីតកាល និងប្រទេសនានាដែលបញ្ហាពលកម្មកុមារក្លាយជាបញ្ហាទូទៅនាពេលបច្ចុប្បន្ននេះ ការពិភាក្សាតុមូលនេះត្រូវបានចូលរួមដោយប្រវត្តិវិទូនៅក្នុងតំបន់ចំនួន ២ រូប និងក្រោមអធិបតីភាពនៃនាយកសាលាចូលនិវត្តិន៍ម្នាក់ ។ ប្រវត្តិវិទូម្នាក់ណិយាយអំពីពលករនៃតំបន់ East Clare ហើយម្នាក់ទៀតណិយាយអំពីការស៊ីឈ្នួល ។ ព្រឹត្តិការណ៍នេះបានធ្វើអោយមនុស្សទាំងចាស់ និងក្មេងបានរួបរួមគ្នា ហើយទទួលការយល់ដឹង និងទំនាក់ទំនងពីជំនាន់មួយទៅជំនាន់មួយទៀត ។

## *ការប្រកួតបាល់ទាត់ "រវាងក្រុមយកចិត្តទុកដាក់ និងក្រុមមិនយកចិត្តទុកដាក់ពលកម្មកុមារ"*

សមាជិកខ្លះគឺជាអ្នកគាំទ្រវិស័យកីឡាបាល់ទាត់ ហើយពួកគេបានសំណូមពរអោយមានបុគ្គលល្បីៗចូលរួមការប្រកួតកីឡានេះ ។ គោលបំណងនៃការប្រកួតនេះ គឺប្រមូលផ្តុំអ្នកដែលអាចទាក់ទាញសាធារណជន និងប្រព័ន្ធផ្សាយអោយមានការចាប់អារម្មណ៍ទៅលើការបង្កើតបរិយាកាសដ៏សប្បាយ និងរាក់ទាក់នេះ ។ ធ្វើការពិភាក្សានៅក្នុងថ្នាក់ដើម្បីស្វែងយល់ថា តើបុគ្គលណាដែលគួរត្រូវទាក់ទង និងទាក់ទងដោយរបៀបណា ។ បុគ្គលដែលមកពីមជ្ឈដ្ឋានកីឡា ដូចជាកីឡាករបាល់អោបជំរើសជាតិអៀរឡង់កីឡាករចោលដុំដែក (កីឡាជាតិរបស់ប្រទេសអៀរឡង់) កីឡាករបាល់ទាត់ដែលត្រូវបង្កើតជាក្រុមដោយមានបញ្ចូលនាយកសាលា និងលោកគ្រូ អ្នកគ្រូមួយចំនួនផងដែរ ។

សំរាប់យុវជនភាគច្រើនដែលបានចូលរួមការប្រកួតនេះគឺជាផ្នែកដ៏សំខាន់នៃសប្តាហ៍នោះ ។ ក្រុមចំនួន ២ ដែលក្រុមមួយមានឈ្មោះថា "ពលកម្មកុមារ" ដែលចូលរួមដោយសិស្សានុសិស្ស ហើយក្រុមម្ខាងទៀត ឈ្មោះថា "ក្រុមព្រងើយកន្តើយនៃពិភពលោក" ដែលចូលរួមដោយបុគ្គលល្បីៗមកប្រកួតគ្នាដើម្បីរកឈ្នះចាញ់ ។ ទោះបីក្រុមទី ២ គឺជាក្រុមខ្លាំងជាងក៏ដោយការប្រកួតត្រូវបានបញ្ចប់ដោយការស៊ុតបាល់ពិន័យប៉េណាំងទី ហើយបាល់ជ័យជំនះត្រូវបានទាត់ចូលដោយក្រុម "ពលកម្មកុមារ" នេះជាការផ្ញើសារដោយសេចក្តីសង្ឃឹមថា បញ្ហាពលកម្មកុមារអាចទទួលជោគជ័យបានទោះជាវាមានលក្ខណៈចំលែកបន្តិចក៏ដោយ ។ ហើយអាជ្ញាកណ្តាលដែលកាត់សេចក្តីការប្រកួតនេះ គឺជាកីឡាករដែលមានឈ្មោះល្បីនៅតំបន់នោះ និងខ្លះទៀតជាគ្រូបង្រៀននៅសាលាបឋមសិក្សាមួយ ។

អ្នកយកព័តិមានកីឡានៅក្នុងតំបន់នោះម្នាក់ ត្រូវបានអញ្ជើញអោយចូលរួមធ្វើជាអ្នកអត្ថាធិប្បាយនៃការប្រកួតនេះពីកន្លែងធ្វើអត្ថាធិប្បាយតាមឧឃោសនស័ព្ទ ។ អ្នកអត្ថាធិប្បាយនោះបានណិយាយកំប្លែងយ៉ាងច្រើនអំពីការប្រកួតដែលវាមានសារៈសំខាន់ខ្លាំងសំរាប់អ្នកដែលចូលរួមទាំងអស់គ្នា ។ បន្ថែមលើនេះទៀតវាបង្កើតនូវទំនាក់ទំនងដ៏ល្អមួយរវាងសកម្មភាព និងប្រព័ន្ធផ្សព្វផ្សាយ ។ អ្នកថតរូបអោយ

កាសែតក្នុងស្រុកម្នាក់ត្រូវបានអនុញ្ញាតអោយថតការប្រកួតនេះ ។ បុគ្គលនិងក្រុមយុវជនក៏បានចូលរួមក្នុងការប្រកួតនេះផងដែរ ។

មានការថ្លែងអំណរគុណចំពោះការផ្សព្វផ្សាយព័ត៌មាន ដែលធ្វើអោយមានការមកជួបជុំដ៏ធំបែបនេះពីសំណាក់ប្រជាជនគ្រប់វ័យនៅក្នុងសហគមន៍ ។ ក្រោយពីការប្រកួតបានចប់បុគ្គលល្បីៗទាំងនោះបានចូលរួមក្នុងពិធីស្វាគមន៍មួយដែលសហគមន៍កុមារ និងប្រព័ន្ធផ្សព្វផ្សាយនានាអាចទាក់ទងគាត់បានដោយផ្ទាល់ ។ នេះគឺជាព្រឹត្តការណ៍ដ៏ជោគជ័យមួយ ហើយវាបានជួយក្រុមមានកំលាំងចិត្តយ៉ាងខ្លាំងដោយសារតែក្រុមយុវជនបានទទួលជ័យជំនះលើគូប្រកួតរបស់ពួកគេ ។

## ល្ខោន

នៅពេលដែលសកម្មភាពនានាបានកើតឡើងនៅក្នុងសប្តាហ៍នៃការយល់ដឹង ក្រុមរបស់ពួកគេក៏បានចូលរួមក្នុងការហាត់សមសំរាប់ការសំដែងរឿងអំពីពលកម្មកុមារ ។ មួយថ្ងៃមុនថ្ងៃសំដែង ក្រុមបានសំដែងមានការតុបតែងសំលៀកបំពាក់នាល្ងាចដែលគេបានអញ្ជើញសហគមន៍ក្នុងតំបន់អោយចូលរួម ។ ការសំដែងនេះគឺជា ផ្នែកមួយដ៏សំខាន់អាចទាក់ទាញទស្សនិកជនអោយជួបជុំគ្នាផង ។ ទស្សនិកជនខ្លះបានស្រក់ទឹកភ្នែក ហើយទស្សនិកជនភាគច្រើនតាមដានយ៉ាងស្ងៀមស្ងាត់ ។ ពួកគេជាច្រើននាក់ពុំមានសេចក្តីសុខទេប៉ុន្តែទស្សនិកជនម្នាក់ៗត្រូវបង្ខំអោយប្រឈមមុខចំពោះខ្លួនឯងតាមរយៈការសំដែងនេះ ។

ដើម្បីបន្តសកម្មភាពទាំងនេះ នៅក្នុងសហគមន៍ និងអោយអ្នកដទៃទៀតចូលរួមក្រុមបានអញ្ជើញក្រុមយុវជនពីសាលាបឋមសិក្សានានានៅក្នុងតំបន់អោយចូលរួមដើរតួផ្សេងៗគ្នា ក្នុងរឿងពលកម្មកុមារនៅខាងក្រៅកន្លែងប្រជុំរបស់ភូមិដែលជាកន្លែងដែលគេនឹងសំដែងរឿងរបស់ពួកគេ ។

ទន្ទឹមនឹងនេះ គ្រប់សមាជិកនៃក្រុមទាំងអស់បានស្លៀកសំលៀកបំពាក់ខ្មៅទាំងអស់ ហើយបានពាក់ស្រោមមុខសិល្បៈពណ៌ស (ដែលពួកគេបានធ្វើដោយខ្លួនពួកគេជាមួយនឹងវិចិត្រករនៅក្នុងតំបន់នៅក្នុងសិក្ខាសាលា) ។ ស្រោមមុខទាំងនោះតំណាងអោយការមិនយកចិត្តទុកដាក់របស់សង្គម ចំពោះការឈឺចាប់របស់កុមារ និងការឈឺចាប់របស់កុមារធ្វើពលកម្ម ។ វាតំណាងអោយក្រុមយុវជនរាប់លាននាក់ដែលទទួលការឈឺចាប់ជារៀងរាល់ថ្ងៃ ។ វាតំណាងអោយសេចក្តីភ័យខ្លាច និងការគ្រប់គ្រងប្រជាជនដោយអាជ្ញាធរមូលដ្ឋាន ។ ក្រុមមានភាពរីករាយពេលរៀនអំពីការធ្វើស្រោមមុខសំរាប់ការសំដែង ហើយពួកគេបានទទួលស្គាល់យ៉ាងឆាប់រហ័សនូវឥទ្ធិពលដ៏ខ្លាំងក្លារបស់វាដែលជួយអោយពួកគេអនុវត្តទៅលើអ្នកដទៃទៀត ។

បន្ទាប់មកទៀតទស្សនិកជនដែលបានប្រមូលផ្តុំនៅខាងក្រៅ និងបានទស្សនា "ការសំដែងល្ខោននៅតាមផ្លូវ" ត្រូវបានអនុញ្ញាតអោយចូលទៅក្នុងបន្ទប់ ។ មានតែមនុស្សម្នាក់ប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតអោយចូលនៅពេលកំណត់ណាមួយ ហើយគាត់ឬនាងត្រូវបានអមដំណើរដោយអ្នកដែលមានពាក់មុខទៅ

កាន់កៅអីណាមួយ ដែលរៀបចំនៅក្នុងបន្ទប់នោះ ។ ប្តីប្រពន្ធត្រូវបំបែកគ្នា (ប៉ុន្តែកូនត្រូវបានអនុញ្ញាតអោយនៅជាមួយឪពុកឬម្តាយ) ហើយពុំមាននរណាម្នាក់ត្រូវបានអនុញ្ញាតអោយណិយាយទេ ។ ប្រសិនបើមាននរណាម្នាក់ណិយាយអ្នកដែលមានពាក់មុខនឹងមកដល់ហើយលើកចង្អុលដៃមួយជាការព្រមាន ។ គោលបំណងធ្វើអោយទស្សនិកជនស្ថិតនៅក្នុងភាពតានតឹងគ្រប់ពេលវេលា ហើយបង្ហាញពួកគេអំពីអារម្មណ៏របស់កូនក្មេងតូចៗដែលត្រូវបង្ខំអោយធ្វើពលកម្ម តើពួកគេមានអារម្មណ៏ដូចម្តេចនៅពេលដែលពួកគេនៅម្នាក់ឯងវង្វេងនៅក្នុងភាពងងឹត បែកពីមិត្តភក្តិ ឬគ្រួសារព័ទ្ធជុំវិញដោយសំលេងចំលែកៗ និងសូរស័ព្ទនៃការងារហើយត្រូវបានបញ្ជាដោយមនុស្សដែលព្រងើយកន្តើយពុំមានការយកចិត្តទុកដាក់ចំពោះពួកគេសោះ ។

នៅខាងក្នុងជញ្ជាំងទាំងអស់នៃបន្ទប់ត្រូវបានដាក់លំអដោយការងាររបស់សិល្បៈករនៅក្នុងតំបន់។ ជាមួយនោះក៏មានដាក់នូវក្រណាត់ដែលគូរដោយដៃរបស់ក្រុមគេផងដែរ ។បង្អួចទាំងឡាយត្រូវបានបិទដោយទុកអោយមានពន្លឺព្រាលៗចូលតែប៉ុណ្ណោះ។ បទភ្លេងត្រូវបានជ្រើសរើសដើម្បីអោយមានភាពព្រឺព្រួច ហើយប្រគុំដោយតន្ត្រីករវ័យក្មេងមួយចំនួនមកពីសាលារៀននៅក្នុងតំបន់ ។

នៅពេលដែលទស្សនិកជនអង្គុយបានស្រួលបួលហើយ អ្នកមានពាក់ស្រោមមុខទៅអង្គុយឯកន្លែងនៅមុខឆាកមុនពេលដែលពួកគេចាប់ផ្តើមសំដែង។ ដោយសាររឿងត្រូវបង្ហាញក្នុងម៉ូឌុលល្ខោនរួចទៅហើយនោះអារម្មណ៏គាំទ្រក៏មិនសូវខ្លាំងឡើយ។ ដូច្នេះពួកសិល្បករក្មេងៗស្ថិតនៅក្នុងសំលៀកបំពាក់ខ្មៅដដែល តែគ្រាន់តែដោះស្រោមមុខចេញនៅក្រោយឆាកប៉ុណ្ណោះ ។

សិល្បករក្មេងៗ អ្នកគ្រប់គ្រងការសំដែង និង ក្រុមសំរបសំរួលបានជួបជាមួយនឹងទស្សនិកជនដែលចង់ប្រាប់ពីអារម្មណ៏ផ្ទាល់របស់ពួកគេ និងចង់ផ្តល់ការលើកទឹកចិត្ត និងការគាំទ្រក្រោយពេលពួកគេបញ្ចប់ការសាកល្បងសំលៀកបំពាក់នេះ ។ ទស្សនិកជនខ្លះប្រើអារម្មណ៏ខ្លាំងពេក ដូចនេះហើយពួកគេមានការពិបាកខ្លាំងណាស់ ក្នុងការបង្ហាញពីអារម្មណ៏ទាំងនោះ។ លទ្ធផលដែលពួកគេកំពុងតែទទួលបាននៅក្នុងសហគមន៏នោះគឺគ្រាន់តែជាការចាប់ផ្តើមប៉ុណ្ណោះសំរាប់ក្រុម ហើយពួកគេចាប់ផ្តើមដឹងថា គំរោងនេះពិតជាបានធ្វើអោយពួកគេមានការយល់ដឹងខុសប្លែកៗគ្នា ។ វាបានដាស់នូវអារម្មណ៏ពិតអំពីអំណួត និងការស្គាល់សមិទ្ធផល ដែលនឹងនៅជាអមតៈជាមួយពួកគេ ។

## រាត្រីវប្បធម៌

សកម្មភាពជាចំបងនៃសប្តាហ៏បង្កើនការយល់ដឹងនេះ គឺការសំដែងចុងក្រោយបង្អស់ដែលត្រូវបានធ្វើនៅក្នុងបរិបទនៃ "រាត្រីវប្បធម៌ពិសេស" ។ កម្មវិធីនេះចាប់ផ្តើមដោយការសំដែងរឿង ហើយបញ្ចប់ដោយពិធីរៀបចំអបអរសាទរវប្បធម៌ជនជាតិអៀវឡង់ និងពិភពលោកនៅក្រោមប្រធានបទពលកម្មកុមារ ។

ល្ខាចនេះគឺជាឱកាសដ៏មានតំលៃ ដើម្បីបង្ហាញអំពីផលប្រយោជន៍គំរោងនេះ ហើយប្រើប្រាស់វាជាឧទាហរណ៍វាស់ស្ទង់គុណភាពនៃអ្វីដែលអាចធ្វើបាននៅពេលដែលការស្រមើស្រមៃ ការអភិវឌ្ឍន៍ និងគំនិតច្នៃប្រឌិត របស់ក្រុមយុវជនត្រូវបានគាំទ្រនៅក្នុងបរិបទនៃយុទ្ធនាការពិភពលោកដើម្បីលុបបំបាត់ពលកម្មកុមារ ។ នៅក្នុងឱកាសនេះពិធីស្វាគមន៍ត្រូវបានរៀបចំដើម្បីទទួលភ្ញៀវ ។ ពេលនោះមានការសំដែងបន្ថែមមួយទៀតដើម្បីបញ្ចប់ពិធី ។ ការសំដែងនេះត្រូវបានរៀបចំឡើងដើម្បីធ្វើអោយអ្នកទស្សនាស្ថិតនៅក្រោមសំពាធរហូតដល់ពេលដែលពួកគេបានចូលដល់កន្លែងធ្វើពិធី ។ នៅពេលដែលគេចាកចេញពីឆាកសំដែងក្រុមបានពាក់ស្រោមមុខរបស់ពួកគេវិញម្តងទៀត ហើយតំរង់ជាជួរតាមផ្លូវនៅខាងក្រៅបន្ទប់នោះទាំងសងខាង ។ នៅពេលចាកចេញពីបន្ទប់នោះទស្សនិកជន នឹងប្រឈមមុខម្តងទៀតជាមួយនឹង ក្រុមពាក់ស្រោមមុខដែលពួកគេបានផ្សឹទៅទុក្ខសោកនៃពលកម្មកុមារ ។ នៅពេលនោះដែរក្រុមដែលមានស្រោមមុខបានអមដំណើរភ្ញៀវទាំងនោះទៅកាន់កន្លែងធ្វើពិធីស្វាគមន៍ ។

ជាថ្មីម្តងទៀត ក្រុមត្រូវបានរំភើបដោយសារតែប្រតិកម្មនានា របស់ទស្សនិកជនដែលបានចាកចេញពីបន្ទប់បន្ទាប់ពីការសំដែងរឿងដោយពិចារណាជិតដាមក្នុងអារម្មណ៍មកជាមួយផង ។ បន្ទាប់ពីការសំដែងមានការថ្លែងសុន្ទរកថា និងការណែនាំដោយរដ្ឋមន្ត្រីនៃរដ្ឋាភិបាលម្នាក់ និងតំណាងជាច្រើននាក់មកពីអង្គការ IPEC និងតំណាងម្នាក់មកពីក្រុមយុវជនដែលបានចូលរួម ។ ក្រុមយុវជនទាំងនោះមានភាពរីករាយយ៉ាងខ្លាំង ហើយមានការដក់ជាប់ក្នុងអារម្មណ៍នូវបទពិសោធន៍អស់នេះ ។ សំរាប់ភ្ញៀវការរៀបចំពិធីល្ខាចនេះមានឥទ្ធិពលយ៉ាងខ្លាំងដល់ពួកគេទាំងអស់គ្នាព្រមទាំងអ្នកសំរេចចិត្តនានា ដែលបានបង្ហាញចំណង់របស់ពួកគេក្នុងការធ្វើគំរោងបែប នេះនៅពេលខាងមុខ ។

ប្រព័ន្ធផ្សព្វផ្សាយមានកាសែតចំនួន ៣ ដែល ២ ជារបស់ជាតិ ហើយ ១ ទៀតជារបស់តំបន់បានផ្សព្វផ្សាយពិធីនោះ និងសកម្មភាពបង្កើនការយល់ដឹងនានា ។ លើសពីនេះទៅទៀត អ្នកយកព័ត៌មានអោយវិទ្យុបានជួប សម្ភាសន៍ ជាមួយភ្ញៀវកិត្តិយសសំខាន់ៗ និងសមាជិកនានានៃក្រុមនោះ ។ បទសម្ភាសន៍នេះត្រូវបានផ្សាព្វផ្សាយតាមរយៈស្ថានីយ៍វិទ្យុក្នុងតំបន់ ។

## គណៈកម្មការដឹកនាំ និងគ្រប់គ្រង

| | |
|---|---|
| ១_លោក ភុង ហានស៊ីន | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ២_លោក តូច ជឿន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក គួច គូលំអ | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៤_លោក ចាប គឹមជុន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក ណុប ទឹម | ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |

## គណៈកម្មការរៀបរៀង និងចងក្រង

| | |
|---|---|
| ១_លោក ភុង ហានស៊ីន | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ២_លោក តូច ជឿន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក គួច គូលំអ | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៤_លោក ចាប គឹមជុន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក ណុប ទឹម | ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៦_លោក ឡុង សុផាត | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |

## គណៈកម្មការបកប្រែ

| | | | |
|---|---|---|---|
| ១_លោកស្រី កង សុថាវី | ប្រធានការិយាល័យក្រោយអក្ខរកម្ម | ២_លោកស្រី តុប ប៊ុនថា | ប្រធានការិយាល័យអក្ខរកម្ម |
| ៣_លោក ញ៉ែម ភីណារ៉េត | អនុប្រធានការិយាល័យរដ្ឋបាល | ៤_លោក តេះ ដាវី | អនុប្រធានការិ.ផែនការនិងគ្រប់គ្រងទិន្នន័យ |
| ៥_លោក ជិន និវត្តន៍ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៦_លោកស្រី ទី វត្តី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៧_លោក ភូ យន់ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៨_លោកស្រី ស្រ៊ុន ម៉ាទី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៩_កញ្ញា អ៊ុក ធារី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ១០_លោក គ្រួច លក្ខិណា | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ១១_លោកស្រី លី ខេង | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | | |

## គណៈកម្មការផ្ទៀងផ្ទាត់

| | | | |
|---|---|---|---|
| ១_លោក សំ ចាន់ទិត | អនុប្រធានការិយាល័យអក្ខរកម្ម | ២_លោក រង់ សូវង្ស | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក ឈុំ ច័ន្ទមុនីរ៉េត | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៤_លោកស្រី ជា សុផល | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក កែវ គង់ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៦_កញ្ញា ម៉ៅ ផល្លី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៧_លោកស្រី ស្រ៊ុន ម៉ាទី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | | |

## គណៈកម្មការឌីហ្សាញ និងកុំព្យូទ័រ

| | |
|---|---|
| ១_លោក ឈិន វិត | ប្រធានការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ២_លោក ពេជ្រ និពន្ធ | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៣_លោកស្រី ឈុំ សោភ័ណ | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៤_លោកស្រី សួច ផាន់ណា | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៥_លោកស្រី ទី រ៉ាដា | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៦_កញ្ញា សន សុម៉ាលី | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |

# ✕ បញ្ឈប់ពលកម្មកុមារ

# Stop Child Labour

**Supporting Children's Rights through Education, the Arts and the Media (SCREAM)**


### សូមថ្លែងអំណរគុណ

- ដល់អង្គការពលកម្មអន្តរជាតិ (ILO) ដែលបានជួយឧបត្ថម្ភថវិកា ក្នុងការបកប្រែ រៀបរៀង និងបោះពុម្ព។
- ចំពោះលោក **មេនណាធីរ ប៉ូល យូសេហ្វ** ប្រធានទីប្រឹក្សាបច្ចេកទេស និងលោក **ថេង ឆវីរិទ្ធ** មន្ត្រីកម្មវិធីនៃ *អង្គការពលកម្មអន្តរជាតិ* (ILO) កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (IPEC) គាំទ្រកម្មវិធីពេលវេលាកំណត់(TBP SP) នៅកម្ពុជាដែលបានជួយផ្តល់ការណែនាំផ្សេងៗ និងការគាំទ្របច្ចេកទេស ព្រមទាំងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងនេះ ដើម្បី **ស្គ្រីម** (SCREAM) កើតមានឡើងនៅកម្ពុជា។

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ យុវជន និងកីឡា តាមសេចក្តីប្រកាស
លេខ 101 អយក ប្រក ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៦



នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ : លេខ ១៦៨ មហាវិថីព្រះនរោត្តម សង្កាត់បឹងកេងកង១
ខណ្ឌ ចំការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** : **(០២៣ ៧២៦ ៥៦៣ / ២១៩ ២៥៨**

**Email** : **nfe@camnet.com.kh**



ISBN-9789995088217